**មជ្ឈមណ្ឌលដើម្បី សន្តិភាព និង អភិវឌ្ឍន៍**

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

Centre for Peace and Development (CPD)
Cambodia Development Resource Institute (CDRI)

# កំណត់ហេតុកិច្ចប្រជុំ ខប់សែលប្រ៉ែម

## យន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ដំណាក់កាលទី ២

**ថ្ងៃព្រហស្បតិ៍ ទី១៦ ខែវិច្ឆិកា ឆ្នាំ២០០៦**

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**ខេត្តស្វាយរៀង**

**ខប់សែល ដំណាក់កាលទី ២**
COPCEL Phase II

*ឧបត្ថម្ភដោយ / Sponsored by*

**កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ**

**United Nations Development Programme (UNDP)**

**របៀបវារៈ**

១. ចំណាប់អារម្មណ៍ស្វាគមន៍ ដោយលោក **ឡារី ស្ត្រេន្ទ** នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

២. បទអន្តរាគមន៍ស្តីពីយន្តការឧបសែលប្រ៉ុម (COPCELPROM) ដោយលោក **ឱក សេរី សោភ័ក្តិ** ទីប្រឹក្សា និងជាអ្នកសំរបសំរួលយន្តការ ឧបសែល នៃវិទ្យាស្ថាន CDRI

៣. ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក **សូរ្យ ទិត្យ** ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តស្វាយរៀង

៤. មតិរបស់អ្នកចូលរួមដែលបង្ហាញពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតនៅក្នុងបរិបទ ខេត្តស្វាយរៀង

៥. សេចក្តីផ្សេងៗ

---

## ១.ចំណាប់អារម្មណ៍ស្វាគមន៍ដោយលោក ឡារី ស្ត្រេន្ទ នាយកប្រតិបត្តិនៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)

បានថ្លែងអំណរគុណដល់ឯកឧត្តម **ជៀង អ៊ី** អភិបាលខេត្តស្វាយរៀង លោក **សូរ្យ ទិត្យ** ប្រធាន លេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តស្វាយរៀង លោក **ទឹម សារ៉ា វុធ** សាកលវិទ្យាធិការនៃសកលវិទ្យាល័យស្វាយរៀង លោក **ចាន់ សុវណ្ណ** អគ្គលេខាធិការនៃ សាលាខេត្តស្វាយរៀង ដែលបានគ្រាំទ្រ និងបានអនុញ្ញាត្តិអោយវិទ្យាស្ថាន CDRI រៀបចំការប្រជុំនៅក្នុងព្រឹកនេះ ។ លោក បាន បញ្ជាក់ថា ជោគជ័យទាំងឡាយរបស់យន្តការឧបសែល គឺអាស្រ័យដោយមានការចូលរួមយ៉ាងសកម្ម និងផុលផុសពីសំណាក់ អស់លោក លោកស្រី ដែលបានចូល រួមនៅក្នុងពេលនេះ ។

វិទ្យាស្ថាន CDRI មានកិត្តិយស និងសេចក្តីរីករាយណាស់ដែលនៅក្នុងការអនុវត្តន៍កម្មវិធី នៃសកម្មភាពរបស់ខ្លួន ដោយទទួលបានការគាំទ្រយ៉ាងពេញទំហឹង និងយ៉ាងសកម្មពីភាគីពាក់ព័ន្ធនានា ជាពិសេសរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ អាជ្ញាធរខេត្ត គជប និងគណកម្មាការរៀបចំការបោះឆ្នោតខេត្តក្រុង អង្គការសង្គមស៊ីវិល និងស្ថាប័នភាគីពាក់ព័ន្ធនានាមួយចំនួន ។

លោក បានជម្រាបជូនថា វិទ្យាស្ថាន CDRI ជាវិទ្យាស្ថានមួយធ្វើការស្រាវជ្រាវដោយឯករាជ្យទៅលើគោលនយោបាយ ដើម្បីរៀបចំគោលនយោបាយសម្រាប់ការអភិវឌ្ឍន៍នៅក្នុងប្រទេសកម្ពុជា ដែលវិទ្យាស្ថាន CDRI មានមូលដ្ឋាននៅទីក្រុងភ្នំពេញ។ វិទ្យាស្ថាន CDRI បានធ្វើការស្រាវជ្រាវទៅលើវិស័យ៥ ដែលជាវិស័យសំខាន់ៗនៅ ក្នុងការជំរុញឱ្យមានការអភិវឌ្ឍន៍ប្រកបដោយចិរភាពដែលមាន ដូចជា សេដ្ឋកិច្ច និងអភិវឌ្ឍន៍ពាណិជ្ជកម្ម ការអភិវឌ្ឍន៍សេដ្ឋកិច្ចតំបន់ ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍វិស័យកសិកម្មជនបទ ការអភិវឌ្ឍន៍ជីវភាពរស់នៅ អភិបាលកិច្ចល្អប្រកបដោយលទ្ធិប្រជាធិបតេយ្យ កំណែទម្រង់រដ្ឋបាលសាធារណៈ ការគ្រប់គ្រងធនធានធម្មជាតិ និងបរិស្ថាន សន្តិសុខមនុស្ស និងការដោះស្រាយទំនាស់ ។ ជាទស្សនៈវិស័យរបស់ វិទ្យាស្ថាន CDRI ដើម្បីឱ្យវិស័យទាំង ៥ ដំណើរការប្រកបដោយភាពរលូន ចាំបាច់ណាស់ក្នុងការកសាងលទ្ធិប្រជាធិបតេយ្យមួយឱ្យបានរឹងមាំ និងពិតប្រាកដក្នុងប្រទេសកម្ពុជា ។ ដោយមើលឃើញពីសារៈសំខាន់នេះហើយបានជា វិទ្យាស្ថាន CDRI បានព្យាយាម និងធ្វើការជាមួយភាគីពាក់ព័ន្ធនានា ជាពិសេស រឿងការងារបោះឆ្នោត ដើម្បីធ្វើយ៉ាងណាជំរុញឱ្យមានការបោះឆ្នោតប្រកបដោយសេរី និងយុត្តិធម៌ ដោយគ្មានហិង្សាព្រមទាំងមានវប្បធម៌នៃការជជែកពិភាក្សា ។

នៅក្នុងវិស័យទាំងអស់នេះ វិទ្យាស្ថាន CDRI បានធ្វើការយ៉ាងជិតស្និតជាមួយគ្រប់ភាគីពាក់ព័ន្ធនៅក្រុងព្រះរាជាណាចក្រកម្ពុជា ។ ជាពិសេសភាគីពាក់ព័ន្ធដែលជាដៃគូរបស់វិទ្យាស្ថាន CDRI មានដូចជារាជរដ្ឋាភិបាល ស្ថាប័ននានាជុំវិញការងារ អភិវឌ្ឍន៍

សង្គមស៊ីវិល ស្ថាប័នឯកជន ស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗផងដែរ ។ វិទ្យាស្ថាន CDRI គឺធ្វើការនៅក្នុងក្របខ័ណ្ឌមួយឯករាជ្យនិង អព្យាក្រឹត្យ ហើយអ្វីដែលវិទ្យាស្ថាន CDRI បានជឿជាក់នៅក្នុងបេសកម្មរបស់ខ្លួននោះ គឺការអភិវឌ្ឍន៍នានាទាក់ទងទៅ និងការ កសាងសន្តិភាព និងអភិបាលកិច្ចល្អប្រកបដោយលទ្ធិប្រជាធិតេយ្យ ដែលជាក្បាលម៉ាស៊ីនមួយដ៏សំខាន់ក្នុងការឈានទៅរកការ អភិវឌ្ឍន៍ ។ វិទ្យាស្ថាន CDRI យល់ថា ការរៀបចំការបោះឆ្នោតដោយរលូនត្រឹមត្រូវ យុត្តិធម៌ និងមានប្រសិទ្ធភាព គឺជាយន្តការ មួយឆ្ពោះទៅរកការកសាងនូវលទ្ធិប្រជាធិតេយ្យមួយដ៏ពិតប្រាកដ ។ ដោយផ្អែកទៅលើទស្សនៈនេះហើយបានជាវិទ្យាស្ថាន CDRI រៀបចំនូវកម្មវិធីកិច្ចប្រជុំ ឧប់សែល ថ្នាក់ជាតិ និងថ្នាក់ខេត្ត ឬ ថ្នាក់មូលដ្ឋាន ដែលអស់លោក លោកស្រី បានចូលរួមនៅពេលនេះ ។ កិច្ចប្រជុំថ្នាក់ខេត្ត បានផ្តល់ឱកាសជូនចំពោះភាគីពាក់ព័ន្ធនានា ជាពិសេសភាគីពាក់ព័ន្ធជុំវិញរឿងបោះឆ្នោត ដើម្បីមានឱកាសលើកយក បញ្ហា ឬការប្រឈមនានា យកមកពិភាក្សានៅចំពោះមុខគ្នា ដោយត្រង់ទៅត្រង់មក និងដោយបើកចំហរ នេះជាចំនុចសំខាន់ របស់ឧប់សែល ។ លោក បានជំរុញឱ្យមានការលើកឡើងនៅបញ្ហាអ្វីៗ ដែលពាក់ព័ន្ធទៅ និងក្តីកង្វល់របស់អ្នកចូលរួមដែលមាននៅ ក្នុងខេត្តស្វាយរៀងនេះ ដោយជំរុញឱ្យមានការលើកយកមកពិក្សាគ្នាត្រង់ទៅត្រង់មក ដោយបើកទូលាយតែម្តង ។ លោក សូមជូនពរ ឱ្យការពិភាក្សាគ្នានេះប្រកបដោយផ្លែផ្កា និងទទួលបានលទ្ធផលជាវិជ្ជមាន ។

**២.បទអន្តរាគមន៍ស្តីពីយន្តការឧប់សែលប្រ៉ម (COPCELPROM) ដោយលោក ឱក សេរី សោភក្តិ៍ ទីប្រឹក្សានិងជា អ្នកសំរបសំរួលយន្តការ ឧប់សែល នៃវិទ្យាស្ថាន CDRI**

លោក **ឱក សេរី សោភក្តិ៍** សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះលោក Larry Strange ដែលបានមាន ប្រសាសន៍ប្រកបដោយអត្ថន័យដ៏ទូលំទូលាយចំពោះវិទ្យាស្ថាន CDRI ក្នុងការរៀបចំយន្តការឧប់សែល ជាពិសេសឧប់សែលប្រ៉ម ។ ឧប់សែលពាក្យពេញគឺយន្តការបង្ការទំនាស់ក្នុងការបោះឆ្នោតនៅកម្ពុជា ។ ដោយ លោក បានធ្វើការតស៊ូនៅជាយដែនចំនួន ១១ ឆ្នាំ ឃើញការលំបាកវេទនា ការស្លាប់ ការដែលប្រជាពលរដ្ឋត្រូវតែធ្វើបាប ហើយវិនាសហិនហោចដោយសារសង្គ្រាម អស់រយៈពេល២៨ ឆ្នាំ ទម្រាំតែយើងក៏សាងបាន មានទឹកភ្លើង មានផ្លូវ បើយើងគិតត្រឡប់ថយក្រោយវិញ គឺការក៏សាងនេះបានមកដោយលំបាកណាស់ ហើយបើសិនជាមានសង្គ្រាមឡើងវិញម្តងទៀត ការរលាយរហ័សណាស់ មិនចាំបាច់ប្រើពេលច្រើនទេ តែមួយភ្លែតបាត់ទៅវិញអស់ ហើយនិងក្លាយទៅជាយុគសម័យខ្មៅងងឹតឡើងវិញទៀត ។ ដូច្នេះគោលបំណងធំរបស់យើងជំនាន់នេះ និងជាមរតកសម្រាប់ខ្មែរ ជំនាន់ក្រោយ ធ្វើយ៉ាងណាកុំឱ្យត្រឡប់ទៅអតីតកាលដ៏សោកសៅនោះទៀត ។ លោក ចេះតែគិតថា តើធ្វើយ៉ាងណា? នៅពេលដែល បានធ្វើជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យរបស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ស ខេង ពីឆ្នាំ ១៩៩៣ រហូតដល់ឆ្នាំ ១៩៩៨ ដែលបាន រៀបចំជាមួយគាត់តាំងពីឆ្នាំ ១៩៩៤មក គឺរៀបចំការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ យើងគ្រោងបោះនៅឆ្នាំ ២០០០ ប៉ុន្តែដល់យឺត យើងជំរុញដល់ឆ្នាំ ២០០២ ទើបបានបោះ ។ ហើយនៅពេលដែលបានបោះរហូតទៅដល់យើងមើលឃើញហើយឆ្នាំ ១៩៩៨, ២០០២ , ២០០៣, ២០០៦ អ៊ុនតាក់រៀបចំឱ្យយើងពី ឆ្នាំ ១៩៩៣ វិទ្យាស្ថាន CDRI បានធ្វើការសិក្សាស្រាវជ្រាវមួយថា ហេតុអ្វីបានជានៅឆ្នាំ ១៩៩៨ ការបោះឆ្នោតមានទំនាស់មានរហូតដល់ការកាប់សម្លាប់ មានរូបភាពមិនល្អនៅទូរទស្សន៍ CNN របស់អាមេរិច ពេញទាំង សកលលោក ធ្វើឱ្យមានរូបភាពកេរ្តិ៍ឈ្មោះរបស់ព្រះរាជាណាចក្រកម្ពុជាអាប់ឱននៅក្នុងឆាកអន្តរជាតិ ។

ឧប់សែល បានរកឃើញទំនាស់មួយចំនួនដែលជាទំនាស់ស៊ីជម្រៅ ហើយ លោក ចេះតែគិតថាធ្វើយ៉ាងម៉េចដើម្បីដោះស្រាយ រឿងទាំងអស់នេះបាន ហើយដោះស្រាយទម្លាប់នៅក្នុងសង្គមខ្មែរយើងដែលនៅមុខគ្នាយើងគួរសមជាមួយនិងគ្នា យើងមិនសូវលើក បញ្ហា យើងច្រើនតែបញ្ចៀសបញ្ហា ប៉ុន្តែនៅក្រោយខ្នងគ្នា គឺយើងនិយាយចាស់ដៃតែម្តង ។ អញ្ចឹងបានជា លោក គិតថាទំនាស់អ្វីៗ ដែលកើតឡើង គឺសុទ្ធតែការមិនយល់គ្នា ការដែលបកស្រាយទៅតាមចិត្តរបស់ខ្លួន ការដែលមិនស្តាប់គ្នាទៅវិញទៅមក ការដែលមិន

ព្រមលើកបញ្ហាទាំងអស់មកដាក់លើតុ ហើយជជែកគ្នាដោយត្រង់ទៅត្រង់មក ។ ក្នុងគំនិតនេះបានជាយើងចាប់ផ្តើមគិតថា គួរតែមានយន្តការមួយបើសិនជាយើងមូលគ្នាថា យើងលេងល្បែងប្រជាធិបតេយ្យមែន យើងគួរតែមានយន្តការមួយដើម្បីនិង បង្ការទំនាស់ យើងមិនបានបង្ការទំនាស់បាន ១០០% ទេ ប៉ុន្តែបើសិនជាយើងមានឱកាសជជែកគ្នា យល់គ្នាទៅវិញទៅមក យ៉ាងហោចណាស់ក៏យើងបានយល់ថា ហេតុអ្វីបានជាអ្នកដ៏ទៃឯទៀត គេមិនឯកភាពជាមួយយើង ហេតុអ្វីបានជាជំហរបស់គេខុសឆ្ងាយពីយើង ការយល់គ្នានេះហើយដែលធ្វើឱ្យយើងទំនាក់ទំនង ហើយបន្តការកសាងនូវ វប្បធម៏ជជែកពិភាក្សាគ្នាទុកចិត្តគ្នា ហើយដោះស្រាយបញ្ហាជាមួយគ្នា ព្រោះបើសិនជាមិនជជែក គឺប្រើកម្លាំងហើយ អស់ពីប្រើដៃគឺ ប្រើអាវុធ តែការប្រើអាវុធ អ្វីដែលយើងខំកសាងមកជាង ១០ ឆ្នាំនិងរលត់រលាយទៅម្តងទៀត ។

អញ្ចឹងហើយបានជាយន្តការឧប់សែលនេះបានបង្កើតឡើងនៅថ្នាក់ជាតិ ពីឆ្នាំ ១៩៩៩ រហូតដល់ឆ្នាំ២០០៣ យើងជំនុំគ្នា ៥០ ដងមួយខែម្តងមិនដែលខានទេ ទោះជាភ្លៀងទឹកលិចក៏ដោយ ។ ដល់យើងធ្វើបាន៥០ ដងអញ្ចឹងទៅបានយើងចាប់ផ្តើមគិតថាគណបក្សនយោបាយធំៗទាំង៣ អង្គការសង្គមស៊ីវិល គជប គណបក្សនយោបាយទាំងអស់ សហគមន៏អន្តរជាតិ រាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង៤ទៀត បានចូលរួមប្រជុំ ដូច្នេះហើយបានជាយន្តការនេះចាប់ផ្តើមឡើង ។ យន្តការនេះគឺធ្វើដោយដៃរបស់ខ្មែរសុទ្ធសាធ មិនបានយកមេរៀនពីណាមកទេ នៅពេលដែលបានគូសវាសយន្តការនេះ ឡើងគឺដោយចិត្តចង់បង្កើតឱ្យមានវប្បធម៏នៃការពិភាក្សាគ្នាកសាងទំនុកចិត្តគ្នា ដោយសារបានឃើញការវិនាសខ្លោចផ្សារ ហើយ១១ ឆ្នាំ នៅជាយដែន លោកឃើញគេធ្វើបាបប្រជាពលរដ្ឋខ្លាំងណាស់ ពិបាកនិងទ្រាំមើលណាស់ ។ លោក បានបញ្ជាក់ថា ការបង្កើតយន្តការឧប់សែលនេះឡើងដំបូង គឺ លោក ទទួលការវាយប្រហារខ្លាំងណាស់ក្នុងឋានៈជាអ្នកបង្កើតយន្តការនេះឡើង ព្រោះមានអ្នកខ្លះចោទ លោក ថា លោក ចូលទៅខាងនេះ ឬចូលទៅខាងនោះ ប៉ុន្តែដោយ៤ឆ្នាំក្រោយមកដោយមានការអត់ធ្មត់ អ្នកណាថាអីយើងចេះតែអត់ធ្មត់ នោះទើបក្រោយមកតួអង្គទាំងអស់យល់ថាយន្តការឧប់សែល នេះមិនបំរើអោយអ្នកណាទាំងអស់ គឺផ្តល់នូវវេទិការមួយដើម្បីជជែកពិភាក្សាគ្នាដោយត្រង់ទៅត្រង់មកមានបញ្ហាអី កុំលាក់ទុយកមកជជែកគ្នានៅលើតុ ។ ដល់ធ្វើបានជោគជ័យអញ្ចឹងទៅ លោក គិតថា ចប់ហើយនៅឆ្នាំ ២០០៣ ក៏ប៉ុន្តែដល់ពេលដែលយើងរៀបចំការបោះឆ្នោត ២០០៧-២០០៨ អង្គការសហប្រជាជាតិ ជាពិសេស លោក Douglas Gardner ដែលទើបតែមកថ្មី គាត់បានមើលសេចក្តីរាយការណ៏ហ្នឹង គាត់បានអាននៅញ៉ូវយ៉ក ហើយបានមកភ្នំពេញ គាត់ថាយន្តការនេះល្អណាស់ ហើយក៏បានមកជួបលោក Larry Strange និងរូបលោក សូមឱ្យធ្វើបន្តទៅទៀត ព្រោះយន្តការបែបនេះមិនមានទេ នៅក្នុងសកលលោក ជាពិសេសនៅប្រទេសដែលចេញពីសង្គ្រាមយូរអង្វែង ហើយចេះបង្កើតយន្តការជជែកពិភាក្សាគ្នាដោយខ្លួនឯង ព្រោះថាវាជាមេរៀននៃការរៀនសូត្រ មិនមែនគ្រាន់តែជាមេរៀនសម្រាប់ប្រទេសកម្ពុជាទេ គឺជាមេរៀនសម្រាប់ប្រទេសថ្មីៗ ដែលទើបតែចេញពីសង្គ្រាមដូចយើងដែរ ។ អញ្ចឹងហើយបានជា UNDP សុំឱ្យយើងធ្វើបន្ត ៣ឆ្នាំទៀត ពីឆ្នាំ ២០០៦ ដល់ ២០០៨ ដូច្នេះយើងក៏ចាប់ផ្តើម ដំណាក់កាលទី២ នេះ ។ ក៏ប៉ុន្តែលោកក៏គិតពិចារណាទៀតថា កាលមុនយើងធ្វើតែនៅថ្នាក់ជាតិ ប៉ុន្តែលើកនេះដល់យើងយកទំនាស់ យកមកវិភាគស៊ីជម្រៅឃើញថា ទំនាស់ដែលខ្លាំងក្លាសស្រាក់សស្រាំ គឺកើតនៅថ្នាក់មូលដ្ឋាន ហើយកាលដែលដោះស្រាយមិនរួចនៅថ្នាក់មូលដ្ឋានធ្វើឱ្យរឿងហ្នឹងក្លាយទៅជារឿងនយោបាយ ដូច្នេះហើយបានលោករំកិលយន្តការ នៅថ្នាក់ជាតិមកថ្នាក់ខេត្ត ទើបបានជាមាន ឧប់សែលប្រ៉ុមនេះ ។ ទាំងឧប់សែលប្រ៉ុមថ្នាក់ជាតិទាំងឧប់សែលថ្នាក់ខេត្តមានគោលបំណងធំៗ៣ៈ

**ទី១.** ធ្វើយ៉ាងណាឱ្យការចុះឈ្មោះបោះឆ្នោតក្លាយទៅជាយន្តការដូចយើងដកដង្ហើម ស្លៀកពាក់ ញ៉ាំបាយអញ្ចឹង ទៅអនាគតលោកបានស្រម័យឃើញថាប្រជាពលរដ្ឋខ្មែរដែលមានអាយុ ១៨ឆ្នាំឡើង មានសៀវភៅក៤ គឺគាត់ដើរទៅស្មៀនឃុំសង្កាត់ក្រុមប្រឹក្សាឃុំសង្កាត់ហើយចុះឈ្មោះតែម្តង លែងឱ្យការចុះឈ្មោះនៅជាបញ្ហាទៀតហើយ ។ នៅស្រុកគេ តែអាយុ ១៨ ឆ្នាំមានកាតមាន

អត្តសញ្ញាណប័ណ្ណទៅចុះឈ្មោះជារឿងធម្មតា មិនត្រូវឱ្យបញ្ហាហ្នឹងទៅជាបញ្ហាទំនាស់កើតបានទៀតទេ ដូច្នេះយើងត្រូវធ្វើយុទ្ធនាការយ៉ាងណាដើម្បីឱ្យការចុះឈ្មោះនេះ ក្លាយទៅជាយន្តការមួយប្រចាំថ្ងៃរបស់យើងតែម្តងទៅអនាគត់ ទោះបីយើងមើលមិនទាន់បានភ្លាម ប៉ុន្តែបើយើងធ្វើការសស្រាក់សស្រាំជាមួយគ្នា នឹងអាចទៅជាអញ្ចឹងបាន ហើយជាសំណូមពររបស់ លោក សូមកុំអោយមានការដូរឈ្មោះ ដើម្បីកុំឱ្យមានបញ្ហាដល់ការចុះឈ្មោះបោះឆ្នោត ។

**ទី២.** ធ្វើយ៉ាងណាឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ដៃប្រជាពលរដ្ឋខ្មែរគ្រប់គ្នាទាំងអស់ ចំពោះអ្នកដែលមានអាយុ ១៨ ឆ្នាំឡើងគឺត្រូវតែបានដល់ដៃ កុំឱ្យមានបញ្ហាយកលុយកាក់ កុំឱ្យយកបញ្ហាហ្នឹងទៅជាថ្លៃ ទាល់តែអ្នកឯងចូលជាមួយខ្ញុំបានខ្ញុំឱ្យប័ណ្ណឬមួយមានបញ្ហារឿងសញ្ជាតិកើតឡើង គឺថាយើងដោះស្រាយបញ្ហាហ្នឹងជាមួយគ្នា ។ អញ្ចឹងហើយបានជាយើងរំភើបណាស់នៅពេលដែលយើងដាក់បញ្ហានៅលើតុជជែកគ្នាជាប់ៗគ្នា ដោយហេតុនេះហើយបានជា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី លោកអានសេចក្តីរាយការណ៍ហ្នឹងទៅ យល់ថាយើងត្រូវតែដោះស្រាយបញ្ហាហ្នឹងហើយ អញ្ចឹងហើយបានជាដើមឆ្នាំ២០០៦ លោករៀបចំនៅយុទ្ធនាការឆ្នាំ ២០០៦ នេះ ដើម្បីឱ្យអត្តសញ្ញាណប័ណ្ណជាតិបានដល់ប្រជាពលរដ្ឋខ្មែរដែលមានចំនួន ១លាន៩សែននាក់ ឱ្យបានគ្រប់ៗគ្នាតែម្តង ។ គ្រប់ខេត្តទាំងអស់មកទល់ខែធ្នូនេះឃើញថា បានចំនួនពី ៨៥% ទៅ ៩០% ហើយ នៅសល់តែ១០% ទៅ ១៥% ដែលក្រសួងមហាផ្ទៃនៅធ្វើបន្តៗទៀត ។

**ទី៣** ចង់ធ្វើយ៉ាងណាអោយគ្រប់តួអង្គទាំងអស់ដើម្បីជជែកពិភាក្សាគ្នា បង្កើតនូវបរិយាកាសសន្តិសុខសុវត្ថិភាព ស្ថេរភាពនៅពេលឃោសនាបោះឆ្នោតនិងធ្វើការបោះឆ្នោត។ ចង់ឱ្យយន្តការនៃការបោះឆ្នោតក្លាយទៅជាទម្លាប់ប្រជាធិបតេយ្យមួយរបស់យើង ជាពិសេសកូនខ្មែរនៅថ្ងៃក្រោយឱ្យលែងមានបញ្ហាអសន្តិសុខ បញ្ហាយប់ឡើងឆ្កែព្រួស ការគំរាមកំហែង ការរើសអើង ហើយសូមអោយយន្តការនៃការបោះឆ្នោតនេះក្លាយទៅជាយន្តការមួយដែលមានសុវត្ថិភាពមិនមានបញ្ហាគំរាមកំហែងនោះទេ បើឈ្នះ គឺឈ្នះដោយការជ្រើសរើសរបស់ប្រជាពលរដ្ឋពិតប្រាកដមែន។

## ៣.ស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោត ថ្លែងដោយលោក សូរ្យ ទិត្យ ប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោត ខេត្តស្វាយរៀង

លោក សូរ្យ ទិត្យ បានបង្ហាញពីស្ថានភាពទូទៅនៃការរៀបចំការបោះឆ្នោតកន្លងមក និងដំណើរការនៃការត្រៀមរៀបចំ និងពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតក្នុងឆ្នាំ២០០៦ ។

**១. អំពីស្ថានភាពទូទៅនៅក្នុងការរៀបចំការបោះឆ្នោតកន្លងមក:** ទី១. ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី១ ក្នុងឆ្នាំ១៩៩៣ ដែលរៀបចំឡើងដោយអ៊ុនតាក់ ។ ក្រោយមកទៀតប្រទេសកម្ពុជាបានដំណើរការបោះឆ្នោត ដោយរៀបចំដោយកម្ពុជាខ្លួនឯងផ្ទាល់ចំនួន ៤លើក ក្នុងនោះមានការរៀបចំការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រចំនួន ២លើក គឺនៅឆ្នាំ១៩៩៨ មានប្រជាជនគ្រប់អាយុចុះឈ្មោះបោះឆ្នោតមានប្រមាណ ៩៤% និងប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតមាន ៩៦% និងឆ្នាំ២០០៣ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលមានប្រជាពលរដ្ឋទៅចុះឈ្មោះប្រមាណ ៩៦% និងប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតមានប្រមាណ ៨៥% ។ ឆ្នាំ២០០២ ការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ប្រជាពលរដ្ឋដែលបានទៅចុះឈ្មោះបោះឆ្នោតមាន ៨៤% ហើយប្រជាពលរដ្ឋដែលបានទៅបោះឆ្នោតមានប្រមាណ ៨៦% ។ ឆ្នាំ២០០៦ ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី២ ដែលជាការបោះឆ្នោតអសកល ដែលបានធ្វើនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៦ ដែលក្នុងនោះក្រុមប្រឹក្សាឃុំមានឈ្មោះបោះឆ្នោតចំនួន៥២១នាក់ ហើយបានទៅបោះឆ្នោតបានគ្រប់ចំនួន៥២១នាក់ ដែលស្មើនិង១០០% ។ លោក បានបញ្ជាក់ថា គជប និង គខប គឺជាអង្គការឯករាជ្យអព្យាក្រឹត្យក្នុងការអនុវត្តន៍កិច្ចការរបស់ខ្លួន ដោយប្រតិបត្តិតាមច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា

បទបញ្ញាតិនីតិវិធីរបស់ គជប ដើម្បីអោយដំណើរការនៃការបោះឆ្នោតប្រព្រឹត្តិទៅដោយសេរី យុត្តិធម៌ និងតម្លាភាព ដែលអាចទទួលយកបាន គឺឋិតនៅក្នុងបរិយាកាសនៃការយោគយល់គ្នា មានការគោរពច្បាប់មិនមានការបំពុលបរិយាកាសសង្គមអោយមានការភ័យខ្លាច គ្មានការគំរាមកំហែង ឬអំពើរហិង្សា និងអសន្តិសុខ ។

លោក កត់សម្គាល់ឃើញថា ក្នុងរយៈកាលនេះនៅមានបញ្ហាទំនាស់មួយចំនួនក្នុងដំណើរការប្រព្រឹត្តទៅនៅក្នុងការបោះឆ្នោត ទី១. ការចុះឈ្មោះអោយអ្នកមានសញ្ជាតិមិនច្បាស់លាស់ មិនគ្រប់អាយុ មានការរើសអើងប្រកាន់បក្សពួក ការបើកការិយាល័យចុះឈ្មោះយឺតពេល តែឈប់មុនពេល ការផ្សព្វផ្សាយពត៌មានមិនបានទូលំទូលាយ ។ ទី២. ក្នុងដំណាក់កាលនៃការឃោសនា មានការរារាំងដំណើរការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ខ្លឹមសារឃោសនា រំលោភលើមាត្រាច្បាប់បទបញ្ញាតិនីតិវិធីរបស់ គជប មានការគំរាមកំហែងលើសមាជិកគណបក្សមិនអោយចូលរួមក្នុងយុទ្ធនាការឃោសនាបោះឆ្នោត ទំលាក់ផ្លាក់គណបក្សនយោបាយបង្ករការរំខានដោយឧឃោសនះស័ព្ទនាពេលឃោសនា ។ ទី៣. ដំណាក់កាលបោះឆ្នោត និងរាប់សន្លឹកឆ្នោត មានទំនាស់មួយចំនួនដូចជាអ្នកបោះឆ្នោតបាត់ឈ្មោះរកឈ្មោះមិនឃើញ មេភូមិនៅរង់ចាំតាមដានមើលអ្នកបោះឆ្នោតនៅការិយាល័យបោះឆ្នោត ដាក់ការិយាល័យបោះឆ្នោតនៅផ្ទះមេភូមិ ពេលរាប់សន្លឹកឆ្នោតលឿនពេក មិនអោយភ្នាក់ងារគណបក្សនយោបាយចូលសង្កេតតាមខ្ទង់រាប់សន្លឹកឆ្នោតបានច្រើនគ្នា ។ មានការកោសលុបលើលិទ្ធផលសំលេងឆ្នោត មិនបានដោះស្រាយបណ្តឹង របស់គណបក្សនយោបាយ ។ ក្នុងដំណាក់កាលពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០០៣ គជប បានប្រជុំគ្នាដើម្បីមើលថា តើទំនាស់ទាំងអស់នេះ កើតឡើងដោយសារអ្វី ? ពេលនោះ គខប មើលឃើញមូលហេតុទំនាស់មាន៤ចំនុច ទី១. ដោយសារការយល់ដឹងនិងការអនុវត្តន៍ច្បាប់ បទបញ្ញាតិនីតិវិធីមិនទាន់បានល្អគ្រប់ជ្រុងជ្រោយ ។ ទី២. មានទិន្នាការនយោបាយច្រើន ។ ទី៣. ខ្វះការយោគយល់អធ្យាស្រ័យអត់អោន អោយគ្នាទៅវិញទៅមក ។

**២.ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៦:** ការត្រៀមសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតមានរយៈពេល៩ខែ ពីខែមករាដល់ខែកញ្ញា ក្នុងរយៈពេលនោះ គឺ គខប បានអោយស្មៀនឃុំ ត្រៀមបំពេញទំរង់បែបបទត្រៀមចុះឈ្មោះបោះឆ្នោត និងស្រង់ស្ថិតិប្រជាពលរដ្ឋ និងការរៀបចំត្រៀមបំរើការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០០៦ ។ ក្នុងដំណើរការនេះ គខប បានអនុវត្តទៅតាមប្រតិទិនរបស់ គជប ការបិតផ្សាយបញ្ជីទីតាំងការិយាល័យបោះឆ្នោត ការិយាល័យចុះឈ្មោះ និងបញ្ជីចុងក្រោយ ។ សកម្មភាពទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ភាគច្រើនជាមន្ត្រីបុគ្គលិកក្របខ័ណ្ឌរដ្ឋ ឯប្រជាពលរដ្ឋធម្មតាវិញច្រើនអោយតំណាងគ្រួសារមកពិនិត្យ ។ លោក បានបញ្ជាក់ថា ការិយាល័យបោះឆ្នោតដែលត្រូវពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះក្នុងឆ្នាំ២០០៦ នេះមាន ៦៤០ការិយាល័យ ។ ក្នុងការចុះឈ្មោះថ្មីក្នុងឆ្នាំ២០០៦ នេះ គខប ចុះបាន ៥៤ពាន់១២៥នាក់ ដែលនៅក្នុងចំនួនតួលេខនេះ លោក បានជំរាបជូនអង្គប្រជុំថា ការគ្រោងគិតរបស់ គខប គឺតែ១ម៉ឺន ៣០០០នាក់ទេ ។ ប៉ុន្តែដល់ចុះឈ្មោះមែនទែន គឺរហូតដល់៥៤ពាន់១២៥នាក់ អ្នកមកកែតំរូវឈ្មោះមាន ១១៧ពាន់៦៦៦នាក់ តំណាងគណបក្សនយោបាយ ដែលដាក់ពាក្យសុំសង្កេតការមាន ៣គណបក្ស គឺគណបក្សប្រជាជនកម្ពុជា គណបក្សហ្វ៊ុនស៊ិនប៉ិច និងគណបក្ស សម រង្ស៊ី ឯអ្នកសង្កេតការជាតិមាន ខមហ្វ្រែល និចហ្វិច និងក្រុមប្រឹក្សាយុវជនកម្ពុជា ។

បញ្ហាសន្តិសុខ ដោយមានទំនាក់ទំនងល្អរវាងលេខាធិការដ្ឋានជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់បានធ្វើអោយដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឆ្នាំ២០០៦ នេះប្រកបទៅដោយសុវត្ថិភាពនិងទទួលបានលទ្ធផលគួរជាទីមោទនៈ ។

បញ្ហាអាកាសធាតុ ក្នុងរយៈកាលចុះឈ្មោះបោះឆ្នោតមានភ្លៀងធ្លាក់ខ្លាំង ថ្ងៃខ្លះភ្លៀងធ្លាក់ពេញមួយថ្ងៃ ធ្វើអោយការបើកការិយាល័យចុះឈ្មោះនៅភូមិខ្លះមានការយឺតយ៉ាវ ដែលធ្វើអោយកើតមានជាបញ្ហាទំនាស់ចោទប្រកាន់ថា មិនមានការបើកការិយាល័យចុះឈ្មោះនៅតាមការិយាល័យមួយចំនួន ។ ការដាក់ទីតាំងការិយាល័យចុះឈ្មោះចល័តនៅផ្ទះមេភូមិ ក្រុមប្រឹក្សាឃុំរង់ចាំបញ្ជាក់

លិខិត ១០១៨ បានធ្វើនៅកន្លែងផ្សេងខុសពីកន្លែងពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ រាល់បញ្ហាទំនាស់ដូច ខាងលើនេះ អាស្រ័យដោយមានការផ្តល់កិច្ចសហការណ៍ផ្តល់ពត៌មានរវាងគណបក្សនយោបាយនានា និងអង្គភាពពាក់ព័ន្ធជាមួយអាជ្ញាធរបោះឆ្នោតបានល្អ និងទាន់ពេលវេលា បានធ្វើអោយដំណើរការសំរបសំរួល និងដោះស្រាយបញ្ហាទំនាស់ទាំងនេះអោយមានភាព ប្រក្រតីស្របតាមនីតិវិធីបទបញ្ជារបស់ គជប ឡើងវិញ ។

ចំពោះការបិតផ្សាយបញ្ជីតំបូង គ្រប់ឃុំមិនមានការបដិសេធការសូមចុះឈ្មោះ និងពុំមានទទួលពាក្យបណ្តឹងទាក់ទងទៅនិងការចុះឈ្មោះលើកលែងតែមួយឃុំ គឺនៅឃុំបរិតចំនួន ៧៥ពាក្យបណ្តឹង ដែលទាក់ទងទៅ និងបញ្ហាសញ្ជាតិ ហើយក្រុមប្រឹក្សាឃុំបរិតបានប្រជុំដោះស្រាយនៅថ្ងៃទី០២ខែវិច្ឆិការឆ្នាំ២០០៦នេះ ដោយយល់ព្រមតាមពាក្យបណ្តឹងចំនួន១៦ ហើយបដិសេធចំនួន៥៩ ។

ការផ្តល់ប័ណ្ណពត៌មានអ្នកបោះឆ្នោត ធ្វើអោយមានភាពងាយស្រួលដល់អ្នកបោះឆ្នោតឱ្យដឹងពីភាពត្រឹមត្រូវ ឬខុសឆ្គងនៃឈ្មោះដែលបានចុះនៅក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋកាន់តែមានការយល់ដឹងនិងភ្ញាក់រលឹកទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ។ គណបក្សនយោបាយផ្តល់កិច្ចសហការណ៍ល្អជាមួយមន្ត្រីលេខាធិការដ្ឋានខេត្ត ដោយបានបំផុសអោយសមាជិក របស់ខ្លួនទៅចុះឈ្មោះបោះឆ្នោតបានច្រើន ។ PEC ក៏ជួបការលំបាកខ្លះដែរ ក្នុងរយៈពេលនេះ ឃុំមួយចំនួនជួបប្រទះនូវការរាំងស្ទះមមាញឹកនៅក្នុងការដកស្ទូង រវល់លក់ដូរ ធ្វើអោយមានការលំបាកក្នុងការរកឱកាសមកចុះឈ្មោះ ។ ការចុះជួយសំរបសំរួលដល់ក្រុមប្រឹក្សាឃុំមិនទាន់បានទាន់ពេលវេលា ព្រោះមធ្យោបាយទាក់ទងនៅមានកំរិត ស្មៀនឃុំមួយចំនួនទើបឆ្លងកាត់ដំបូងនូវការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅក្នុងខេត្តស្វាយរៀងនេះមានស្មៀនឃុំមួយចំនួនគាត់មកកាន់ការថ្មីតែម្តង ដោយសារស្មៀនឃុំចាស់គាត់លាឈប់ ឬមានធុរៈផ្សេងៗទៀត ។ លោក បានបញ្ជាក់ជូនថា ពីពេលនេះរហូតទៅដល់ថ្ងៃបោះឆ្នោត PEC មានការងារសំខាន់៣គឺ:

ទី១ ការសុំទទួលពាក្យសុំចុះបញ្ជីរបស់បេក្ខជនគណបក្សនយោបាយ ពីថ្ងៃទី ០១ ដល់ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ ២០០៧ ដែលមានរយៈពេលតែ ៣ថ្ងៃគត់ រីឯការឃោសនាយើងត្រូវឃោសនាពីថ្ងៃទី ១៦ ដល់ ថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៧ ។ ហើយថ្ងៃសំខាន់ដែលយើងត្រូវបោះឆ្នោត គឺថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ។ លោក សង្ឃឹមថា បញ្ហាទំនាស់ដែលកើតពីឆ្នាំកន្លងមកនេះ និងមានការថយចុះជាលំដាប់ ប៉ុន្តែយើងមិនសង្ឃឹមថា យើងអាចជៀសផុតពីទំនាស់បានទេ តែយើងអាចនឹងជួបនូវទំនាស់ថ្មីៗផ្សេងទៀតនៅចំពោះមុខ ដូច្នេះយើងនិងរួមសហការណ៍គ្នាលើកឡើង នឹងរួមគ្នាដោះស្រាយទាំងអស់គ្នា ។

## ៤.មតិរបស់អ្នកចូលរួមដែលបង្ហាញពីការប្រឈមទាំងឡាយក្នុងយន្តការរៀបចំការបោះឆ្នោតនៅក្នុងបរិបទខេត្តស្វាយរៀង

លោក **យ៉ែម ហែន** សមាជិកក្រុមប្រឹក្សាឃុំដូនស ស្រុកស្វាយជ្រុំ គណបក្ស សម រង្ស៊ី បានធ្វើការចាប់អារម្មណ៍ទៅលើរបាយការណ៍របស់ លោក សូរ្យ ទិត្យ ថា ជាការត្រឹមត្រូវ ប៉ុន្តែអ្វីនឹងកើតមានឡើងនៅពេលដែលចេញទៅធ្វើការបោះឆ្នោត? លោក បានបញ្ជាក់ថា ប្រជាពលរដ្ឋនៅក្នុងឃុំ លោក ក៏មិនខុសពីប្រជាពលរដ្ឋនៅក្នុងខេត្តស្វាយរៀង ទាំងមូលដែរ ដែលជាខេត្តមួយចំណាកស្រុកចេញទៅរកធ្វើការនៅខាងក្រៅច្រើន អញ្ចឹងនៅពេលបោះឆ្នោតថ្ងៃ០១ ខេមេសាឆ្នាំ២០០៧ ខាងមុខនេះ លោក គិតថា ចំពោះកម្មករដែលបានបំរើការងារនៅតាមរោងចក្រដែលឆ្ងាយពីខេត្ត ជួបបញ្ហាលំបាកនៅពេលដែលត្រឡប់មកបោះឆ្នោតវិញ ។ បញ្ហាលំបាកនេះមិនមែនមកពីថៅកែរោងចក្រ ឬការអនុញ្ញាតិច្បាប់នោះទេ គឺបញ្ហាដោយសារនៅក្នុងខែមេសានេះគាត់ត្រូវធ្វើការវិលត្រឡប់ពីរសារ លើកទី១ គឺគាត់មកបោះឆ្នោត លើកទី២ គាត់ត្រូវវិលត្រឡប់មកវិញនៅថ្ងៃចូលឆ្នាំ អញ្ចឹងក្នុងមួយខែនេះគាត់ត្រូវមកពីរដងដូច្នេះក្នុងរយៈពេលនេះតំម្លៃសេវាអ្នកឆ្លៀតឱកាសនិយមឡើងកាន់តែខ្ពស់ គឺតំម្លៃឡានតាក់ស៊ីនេះឯង ។ ដូច្នេះ លោក រំពឹងគិតថា នៅពេលបោះឆ្នោតខាងមុខ ទោះបីជាការចុះឈ្មោះមានគុណសម្បត្តិបានច្រើនមែន ប៉ុន្តែវាអាចប៉ះពាល់ដល់កិច្ចការងារនេះ ។ ទាក់ទង

និងការចូលសង្កេតការណ៍ លោក ចាប់អារម្មណ៍ថា នៅពេលរាប់សន្លឹកឆ្នោត នីតិវិធីនៃការរាប់សន្លឹកឆ្នោតនៅពេលនោះឃើញថា ក្រុមអាណត្តិទី១ នេះបានរាប់នៅថ្នាក់ឃុំ ពេលរាប់បានហែរសន្លឹកឆ្នោតមកផ្តុំបង្កើតជាការិយាល័យរាប់សន្លឹកឆ្នោតនៅកន្លែងមួយ ពេលនោះដូចគាត់បានមានប្រសាសន៏ហើយថា នីតិវិធីច្បាប់បានកំណត់ថា អ្នកចូលសង្កេតការណ៍នៅពេលរាប់ច្បាប់បានកំណត់ អញ្ចឹងពេលដែលរាប់ពិតមែនតែរាប់តែមួយកន្លែង ប៉ុន្តែការិយាល័យដែលចុះនៅក្នុងការិយាល័យរាប់នេះ គឺមាន៤ មាន៥ ឬអាចមានច្រើនលើសពីនេះ ។ អញ្ចឹងភ្នាក់ងារសង្កេតការណ៍ជួនកាលអាចចូលមួយ ឬអាចចូលបានពីរ ដូច្នេះមនុស្សម្នាក់មិនអាចរំពឹងទៅលើការិយាល័យទាំងអស់នោះបានទេ មនុស្សពីរនាក់មិនអាចមើលទាន់បានទេ ។ លោក ក៏សូមឯកភាពផងដែរ ដែល លោកប្រធាន PEC បានមានប្រសាសន៏ថា មិនអាចបង្ហាញអោយឃើញជាក់លាក់នូវស្នាមគំនូសនៃការគាំទ្ររបស់អ្នកទៅបោះឆ្នោត អញ្ចឹងបញ្ហានេះ គឺជាបញ្ហាត្រឹមត្រូវណាស់ ។ លោក គិតថា នៅពេលរាប់នៅក្នុងឆ្នាំ ២០០៧ ខាងមុខនេះសូមអោយ គជប រៀបចំ នៅឃុំណាបង្កើតអោយមានប៉ុន្មានការិយាល័យសម្រាប់រាប់ ត្រូវអោយមានភ្នាក់ងារ ឬមួយតំណាងសង្គមស៊ីវិលអោយបានឃើញអោយបានច្បាស់ផង ។

លោក **ឱក សេរី សោភក្តិ៍** បញ្ហារឿងចុះឈ្មោះលើសចំនួននេះ ជាបញ្ហាជាតិទាំងមូល យើងបានធ្វើការប្រជុំឧប់សែលនៅថ្នាក់ជាតិហើយ គជប បានរាយការណ៏ថា ការដែលត្រៀមលក្ខណៈដើម្បីបំរើការពិនិត្យឈ្មោះ និងចុះឈ្មោះនេះ គឺតែ៦០ម៉ឺនទេ តែដល់ពេលចុះជិត១លាន ។ ចំនួនប្រជាពលរដ្ឋដែលខុសខ្លាំងដល់ថ្នាក់នេះ គឺមានន័យថា នៅថ្នាក់ឃុំសង្កាត់យើងក្តាប់មិនបានទេ ជាពិសេសគឺការចំណាកស្រុកដោយសារមូលហេតុសេដ្ឋកិច្ច ។ ដូច្នេះហើយ លោក សូមជំរាបទៅក្រុមប្រឹក្សាឃុំសង្កាត់ ការដែលក្តាប់ចលនាប្រជាពលរដ្ឋ និងចំនួនប្រជាពលរដ្ឋ គឺឋិតនៅក្នុងដៃរបស់ អស់លោក លោកស្រី បើសិនយើងក្តាប់តួលេខនេះមិនបានថា អ្នកណានៅទីណា សមាជិកគ្រួសារប៉ុន្មាននាក់មិនបាន ក្រសួងមហាផ្ទៃក៏ធ្វើផែនការណ៏ខុស គជប ក៏ធ្វើផែនការណ៏ខុស សង្គមស៊ីវិលដែលរៀបចំផែនការណ៏ សម្រាប់សុំជំនួយសម្រាប់បំរើការនេះក៏ខុស ខុសនាំគ្នាខុសតគ្នាទាំងអស់តែម្តង ។ ហើយទំរង់ ១០១៨ គឺ គជប អោយមកខ្វះ រាប់ពាន់សន្លឹកក្នុងមួយខេត្តៗ ទាល់តែអង្គការសង្គមស៊ីវិលខ្លះ បានបោះពុម្ពបន្ថែមចែកផ្សាយ ដូច្នេះការក្តាប់ចលនាប្រជាជលរដ្ឋ និងចំនួនប្រជាពលរដ្ឋមិនបានដោយក្រុមប្រឹក្សាឃុំសង្កាត់ជះឥទ្ធពលទៅលើនយោបាយថ្នាក់ជាតិនោះខ្លាំងសំបើមណាស់ ។ ដូច្នេះ លោក គិតថា គួរតែក្រុមប្រឹក្សាឃុំសង្កាត់ធ្វើការពិនិត្យឡើងវិញថា តើក្តោបក្តាប់ចលនាប្រជាពលរដ្ឋយ៉ាងណានៅក្នុងឃុំនិមួយៗ។

លោកស្រី **អ៊ុំ ជាក់** ជំទប់ទី១ ឃុំព្រៃអង្គុញ ស្រុកចន្ទ្រា គណបក្ស ហ៊្វុនស៊ិនប៉ិច បានលើកឡើង៣ចំនុចៈ ទី១. រឿងកម្មកររោងចក្រ គឺថ្ងៃបោះឆ្នោតវាជិតថ្ងៃចូលឆ្នាំពេកហើយឡានតាក់ស៊ីឡើងថ្លៃ ។ ទី២. រឿងអត្តសញ្ញាណប័ណ្ណដែលទើបតែធ្វើថ្មីៗនេះនៅឃុំនាង លោកស្រី អ្នកដែលធ្វើអត្តសញ្ញាណប័ណ្ណមានចំនួន ១១៩៧នាក់ ប៉ុន្តែទទួលបានតែ ៨៥៦នាក់ទេ ហើយអ្នកដែលទទួលមិនបាននេះ គឺសុទ្ធតែជាគណបក្សផ្សេងពីគណបក្សប្រជាជន ហើយមេភូមិដែលធ្វើការរាល់ថ្ងៃនេះបំរើតែគណបក្សមួយ ហើយមានការយកលុយកាក់ទៀត ដូចជាភូមិប្រាសាទរបស់ លោកស្រី អត្តសញ្ញាណប័ណ្ណមួយ គឺយក ៥០០រៀល ។ ទី៣. ការខ្វះទំរង់១០១៨ ដែលមានទាក់ទងទៅ និងរូបថតដែលរូបថតហ្នឹងនៅពេលបំពេញច្រើនពេកដល់ពេលបោះឆ្នោតហើយនោះ តើធ្វើម៉េចនឹងបំពេញទាន់? ដើម្បីអោយគាត់បានទៅបោះឆ្នោត ។

លោកស្រី **រ័ត្ន វណ្ណា** ក្រុមប្រឹក្សាឃុំស្វាយរៀង គណបក្ស ហ៊្វុនស៊ិនប៉ិច ទាក់ទងនិង ១០១៨ អោយបានបោះឆ្នោត ប៉ុន្តែខាងសមត្ថកិច្ចដែលចុះថតអត្តសញ្ញាណប័ណ្ណ គាត់មិនបានថតអត្តសញ្ញាណប័ណ្ណអោយទៅឈ្មោះ ក ឈ្មោះខ ដែលបានចេញអត្តសញ្ញាណប័ណ្ណអោយទេ ព្រោះបញ្ហាគាត់ថា គាត់មិនគ្រប់អាយុ ។ លោកស្រី សូមសួរថា នៅពេលបោះឆ្នោត ខាងមុខនេះតើមានវិធានការណ៏ដោះស្រាយយ៉ាងម៉េច? អោយសមាជិកខាងគណបក្សរបស់ លោកស្រី បានបោះឆ្នោត លោកស្រសំណូមពរអោយចេញជាឯកសារអ្វី

មួយផ្សេងទៀតដើម្បីអោយបានបោះឆ្នោត ព្រោះគាត់បានទទួលតែ១០១៨ តែអត្តសញ្ញាណប័ណ្ណគាត់ថតមិនបានទេ ។ ហើយការចេញ ១០១៨ នោះបើចេញមិនទាន់ទេ ដល់ពេលបោះឆ្នោតហើយនោះ តើ PEC ដោះស្រាយ យ៉ាងណា ?

ហើយនៅក្នុងមូលដ្ឋាន លោកស្រី ក៏មិនខុសពីមូលដ្ឋានដទៃទៀតដែរ គឺកំរិតនៃប្រជាពលរដ្ឋមានការកើនហួសពីការស្មានពេលនេះ គាត់ប្រហែលជាចង់បាននូវអត្តសញ្ញាណប័ណ្ណ ដើម្បីកាន់សំគាល់ខ្លួន ដូចជាកម្មកររោងចក្រខ្វះខាត ប៉ុន្តែដល់ពេលការបោះឆ្នោតគាត់មិនបានគិតថា កាតព្វកិច្ចរបស់គាត់ជាពលរដ្ឋត្រូវមកបោះឆ្នោត ឬមួយយ៉ាងម៉េច? បើតាម លោកស្រី សន្និដ្ឋាន គឺថា គាត់ចង់បានតែអត្តសញ្ញាណប័ណ្ណប៉ុណ្ណោះឯង ។ ដូច្នេះការបោះឆ្នោតគឺមិនអាចធ្វើទៅបានតាមសំលេងដែលយើងបានមកទេ ។

លោក **ឱកសេរី សោភក្តិ** ចំពោះរឿងចេញលិខិត ១០១៨នោះ គឺមិនលំបាកទេ មានការងាយស្រួលណាស់ តែបញ្ហាដែលយើងជួបប្រទះនោះ គឺប្រជាពលរដ្ឋ លោក មិនមានរូបថត បញ្ហានេះហើយដែលយើងត្រូវដោះស្រាយអោយទាន់ ។

លោកស្រី **ទេព សោមុន្នី** មេឃុំ គោកព្រីង ទាក់ទងនិងបញ្ហារូបថតនេះឃុំ លោកស្រី មានរូបថតបិត ១០១៨អស់ហើយ ប៉ុន្តែរូបថតនោះមានតូចមានធំ អញ្ចឹងដល់ពេលបោះឆ្នោតតើនៅក្នុងការងារបោះឆ្នោតអាចអោយបោះឆ្នោតបានដែរ ឬទេ?

លោក **ភោគ ឈន ក្រុមប្រឹក្សាឃុំគ្រួស** បញ្ហាអត្តសញ្ញាណប័ណ្ណ ពេលដែលស្នងការរៀបចំកំលាំងចុះទៅធ្វើអត្តសញ្ញាណប័ណ្ណនៅតាមឃុំ គឺមន្ត្រីដែលចុះទៅធ្វើការនោះគាត់យកលុយច្រើនពីប្រជាពលរដ្ឋ រហូតដល់ប្រជាពលរដ្ឋមិនចង់ទៅធ្វើដោយគ្មានថវិការ ។

លោកបានចូលរួមផ្តល់អនុសាសន៍ថា ដើម្បីបង្ការទំនាស់នៅពេលខាងមុខនេះ លោក សុំស្នើរដល់ប្រធានលេខាធិការដ្ឋានចាត់ចែងធ្វើយ៉ាងណាកុំឱ្យមានបញ្ហាអសន្តិសុខ ដូចជាការគំរាមកំហែងប្រដាប់អាវុធជាដើម ។ ជាក់ស្តែងឥឡូវនេះ គឺនៅសល់មានតិចតួចបញ្ហាមេភូមិដើរយកចំលើយពីប្រជាពលរដ្ឋថា បោះអោយអ្នកណា មេភូមិ នឹងឡើងទៅជួបជាមួយប្រជាពលរដ្ឋថា អ្នកឯងត្រូវតែចុះចូលជាមួយគណបក្សមួយទៅ ដើម្បីបានអំណោយ ដូច្នេះ លោក សូមស្នើរធ្វើយ៉ាងណាដើម្បីអោយមានតម្លាភាពក្នុងការបោះឆ្នោតនៅថ្ងៃខាងមុខ ។

លោកស្រី **សុខ ណន** ក្រុមប្រឹក្សាឃុំស្វាយទាប គណបក្ស ប្រជាជន សំនូមពរថា មុននឹងបិតការិយាល័យបោះឆ្នោត សូមអោយដល់ម៉ោងព្រោះកន្លងមក គឺមិនទាន់ដល់ម៉ោងផងបិទ ដូច្នេះធ្វើអោយសល់មនុស្សគ្រប់ការិយាល័យ ដែលនៅមិនទាន់បានបោះឆ្នោត។

លោក **ប្រាជ អាន** ជំទប់ទី២ ឃុំបាវិត ស្រុកចន្ទ្រា គណបក្ស សម រង្ស៊ី លើកឡើងនូវ ៣ចំនុច គឺទី១ បញ្ហាធ្វើអត្តសញ្ញាណប័ណ្ណ ក្នុងភូមិ លោក មានប្រជាពលរដ្ឋគាត់ទៅប្តឹងថា មានកាសែតណាគេចុះថា មានមន្ត្រីធ្វើអត្តសញ្ញាណប័ណ្ណមានការយកលុយ លោក សួរថា កាសែតចេញលេខប៉ុន្មាន នៅថ្ងៃណា ខែណា ក្នុងនោះបានប្តឹងដល់រូប លោក ដែលជាជំទប់ទី១ ទី២ ខាងគណបក្ស សម រង្ស៊ី ថា មានយកលុយនោះ ខាង លោក ថា មិនមានទេ លោក មិនបានផ្តល់ទេគ្រាន់តែឃើញថា មន្ត្រីហ្នឹងមានលុយដាក់ខាងមុខមែន ប៉ុន្តែមិនមែនជាលុយគេជូនគាត់ទេ គឺជាលុយគាត់ ដែលដាក់នៅលើតុ ដល់ប្រជាពលរដ្ឋគាត់ឃើញលុយនោះគាត់ថាមន្ត្រីស៊ីលុយ ។

ចំពោះការចុះចែកប័ណ្ណពតិមាន និងសៀវភៅពតិមាន នៅឃុំ លោក មានតែ៥ឃុំទេ ហើយមាន១០ភូមិ ដល់អញ្ចឹងទៅប្រជាពលរដ្ឋគាត់មើលប័ណ្ណពតិមានថា ម៉េចបានជាភូមិនេះខុសអញ្ចឹង ហើយខ្លះក៏ខ្ជិលទៅ ដូច្នេះហើយមិនបានទៅចុះ ឈ្មោះបោះឆ្នោតទេ ពិសេសអ្នកដែលមិនមាន១០១៨ និងខ្វះរូបថតទៀតនោះ។

លោកស្រី **គង់ ចាន់ធឿន** សមាជិកក្រុមប្រឹក្សាឃុំសំបួរ ស្រុកស្វាយទាប អំពីអ្នកចុះឈ្មោះអ្នកដល់អាយុ នៅឃុំនាង លោកស្រី គឺចុះបានល្អណាស់ ប៉ុន្តែគ្រាន់តែយឺតខាងរូបថតគាត់យកមកមិនទាន់ ហើយឥឡូវគាត់យកមកបិត បានមួយចំនួនហើយនៅសល់តិចតួចទេ ។ ហើយការចុះឈ្មោះលើកទី២ នេះនៅថ្ងៃទី០១ដល់ថ្ងៃទី២៤ គឺថាបានល្អ ទាំងរូបថតគឺគាត់យក មកព្រមគ្នា ហើយ

បាន ១០១៨ ទៅចុះអត្តសញ្ញាណប័ណ្ណ ឃុំនាង លោកស្រី ថាធ្វើតែ២ថ្ងៃទេដល់ប្រជាពលរដ្ឋច្រើនធ្វើ៤ថ្ងៃបានចប់ ។ ប៉ុន្តែ លោកស្រី ចាប់អារម្មណ៍រឿងបញ្ហាយកលុយកាក់គ្រប់កន្លែង មួយកន្លែង៥០០រៀលមិនយកទេ យក ១០០០រៀល អញ្ចឹងបើ ១០កន្លែងមិន ១០០០រៀល ។

លោក **ខៀវ សុខុម** នាយរងសេនាធិការ នរគលបាលខេត្តស្វាយរៀង អំពីការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋនៅក្នុងខេត្តស្វាយរៀង ។ ក្រុមការងារ លោក បានខិតខំប្រឹងប្រែងក្នុងការផ្តល់អត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ ដើម្បីបំរើការអោយការបោះឆ្នោតនៅក្នុងពេលខាងមុខនេះ ។ ការផ្តល់អត្តសញ្ញាណប័ណ្ណនេះ លោក ផ្តល់បានចំនួន ៣១៨ពាន់៤៨៦នាក់ ហើយក្នុងនោះ គឺបានចែកជូនប្រើប្រាស់រួចហើយចំនួន ២៧៣ពាន់៧០៩នាក់ ហើយនៅសល់មិនទាន់ផលិតបានប្រមាណជា ៤ម៉ឺននាក់ទៀត ។ ចំនួនតួលេខនេះបើធ្វើការប្រៀបធៀបទៅនិងចំនួនរបស់លេខាធិការដ្ឋានរៀបចំការបោះឆ្នោតខេត្តឃើញថា មានភាពខុសគ្នា ដោយខាងនគរបាល លោក មានតួលេខច្រើន ខាង PEC គឺមាន៣០៨ពាន់នាក់ជាង ហើយខាងនរគលបាល អ្នកមានអាយុ១៨ ឆ្នាំឡើងមាន ៣១៧ពាន់២៥៩នាក់ ហើយការផ្តល់អត្តសញ្ញាណប័ណ្ណនេះ គឺលើសពីចំនួនប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើងទៅទៀត ។ នេះដោយសារតែក្រុមជំនាញបានផ្តល់ជូនប្រជាពលរដ្ឋដែលមានអាយុនៅមិនទាន់គ្រប់ដូចជាខ្វះ ២-៣ខែ អញ្ចឹងទៅ ហើយចំនួននេះមិនទាន់បានបូកសរុបទៅនិងចំនួនប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំ ហើយម្យ៉ាងទៀតអ្នកខ្លះគាត់ធ្វើ២ដង ដោយធ្វើលើកមុនបាត់ អញ្ចឹងទៅ គឺគាត់មកធ្វើម្តងទៀត ហើយខ្លះទៀតគាត់ធ្វើខុសអញ្ចឹងទៅ ។

ពាក់ព័ន្ធនិងការផ្តល់អត្តសញ្ញាណប័ណ្ណនេះ តាមការពិតទៅ គឺថ្នាក់ដឹកនាំស្នងការពុំមានអនុញ្ញាតិអោយក្រុមជំនាញ ចុះធ្វើអត្តសញ្ញាណប័ណ្ណយកលុយពីប្រជាពលរដ្ឋទេ ។ ខាង លោក បានដាក់វិធានការយ៉ាងម៉ឺងម៉ាត់ណាស់ចំពោះរឿងនេះ ហើយកន្លងមកក៏ធ្លាប់មានបណ្តឹងខ្លះដែរពីរឿងនេះ ហើយខាងស្នងការដ្ឋាននរគលបាលខេត្ត លោក ក៏បានចាត់មន្ត្រីចុះទៅធ្វើការស៊ើបអង្កេតស្រាវជ្រាវទៅលើបញ្ហានេះជាបន្ទាន់ផងដែរ ។ ឆ្លងតាមការស្រាវជ្រាវនៅមូលដ្ឋាន ការសាកសួរប្រជាពលរដ្ឋផ្ទាល់ ឃើញថាគាត់បាននិយាយថា ការដែលគាត់អោយលុយនេះមិនមែននរគលបាលគាត់ទៀមទារទេ   គឺគាត់មានមនោសញ្ចេតនាជាមួយកំលាំងប៉ូលិសដែលធ្វើអត្តសញ្ញាណប័ណ្ណនេះ គឺគាត់ជូនម្នាក់៥០០រៀល អ្នកសរសេរប័ណ្ណពតិមាននោះ ៥០០រៀល សរុបទៅអស់១៥០០-២០០០រៀល នេះមិនមែនជាការទៀមទារថា ត្រូវតែបង់លុយប៉ុណ្ណេះប៉ុណ្ណោះទេ ។

លោក **សួរ្យ ទិត្យ** ទាក់ទងនិងបញ្ហាសំនួរទាំងអស់ លោក សុំធ្វើការឆ្លើយបំភ្លឺដូចតទៅ:

ទី១ បញ្ហាសង្កេតមើលតាមការិយាល័យរាប់សន្លឹកឆ្នោត លោក បានបញ្ជាក់ថា PEC ធ្វើអ្វីក៏ដោយគឺមានច្បាប់ មានបទបញ្ជានីតិវិធីតែបើយើងធ្វើអោយលើសក្របខ័ណ្ឌនេះ គឺពិបាកទទួលយកបានណាស់ ។ ព្រោះបន្ទប់ដែលរាប់សន្លឹកឆ្នោតនោះ មានកំណត់បើយើងអោយចូលតាមចិត្តដែលយើងចង់នោះ មិនអាចយកកន្លែងនោះធ្វើការបានទេ អញ្ចឹងហើយបាន គជប កំណត់អោយអ្នកចូលមើលការសង្កេតការណ៍រាប់នោះមិនអាចចូលបានតាមចិត្តទេ ។

ទី២ បញ្ហា១០១៨ មានអ្នកខ្លះគាត់ភ័យព្រួយថា ខ្លាចធ្វើមិនទាន់ មិនមែនធ្វើមិនទាន់ទេ ខ្លាចខ្វះរូបថត លោកបានបញ្ជាក់ថា ថ្ងៃនេះក៏អាចធ្វើបាន ស្អែកក៏ធ្វើបានដែរ ធ្វើរហូតដល់ថ្ងៃបោះឆ្នោត ដូច្នេះយើងមានពេលវេលាច្រើនណាស់សម្រាប់ លោក លោកស្រី ដែលជាក្រុមប្រឹក្សាឃុំដែលជាអ្នកចេញជូនប្រជាពលរដ្ឋ ។ ហើយរូបថតនោះទៀតមិនគិតថា តូច ឬធំទេអោយតែជារូបថតរបស់គាត់ យកមកបិតនៅក្នុង ១០១៨ គឺបោះឆ្នោតបានហើយ ។

ទី៣ បញ្ហាមេភូមិដើរយកចម្លើយពីប្រជាពលរដ្ឋ លោកបានបញ្ជាក់ថា គោលការណ៍ប្រជាធិតេយ្យមិនអាចធ្វើអញ្ចឹងបានទេ ។ ការបោះឆ្នោតសេរីនិងយុត្តិធម៌ផ្អែកទៅលើល័ក្ខខ័ណ្ឌមួយចំនួន គេថា បោះឆ្នោតជាសំងាត់ គ្មាននរណាម្នាក់ចង់ដឹងថា អ្នកណាបោះឆ្នោតអោយអ្នកណាទេ បើមានការកើតឡើងដូច្នេះមែន គឺជាអំពើរខុសច្បាប់ហើយ ខុសគោលការណ៍ប្រជាធិតេយ្យហើយ ។

ទី៤ ការចុះចែកប័ណ្ណពតិមាន ថា ឃុំបរិក មាន៩ភូមិ ហើយការចែកប័ណ្ណពតិមាននេះ ដើម្បីអោយបានទទួលប័ណ្ណពតិមាននេះ លោក ពិនិត្យមើលបើឃើញថា ខុសមិនត្រឹមត្រូវ លោក ទៅជួបស្មៀនឃុំដើម្បីធ្វើការកែតំរូវ ។ ទោះបីកែហើយមិនបានគ្រប់គ្រាន់ក៏លោកមានមោទនភាពដែរព្រោះឆ្នាំនេះបាន ១១៧នាក់ ប៉ុន្តែរាល់ឆ្នាំលោកជឿថា អត់ដែលទៅមើលនោះតិចភាគរយណាស់ ដែលបងប្អូនទៅមើលឈ្មោះ ខ្លាចឈ្មោះខ្លួនខុស ប៉ុន្តែឆ្នាំនេះបាន ១សែនជាងលើបញ្ជីចាស់ យើង២សែន៩ម៉ឺននោះឃើញថា ជាមោទនភាពណាស់ ។ ការផ្តល់ប័ណ្ណពតិមានមានសារៈសំខាន់ណាស់ គឺអោយប្រជាពលរដ្ឋដឹងថា ខ្លួនខុសអាយុ ខុសភេទ ខុសការិយាល័យ ខុសភូមិអីអញ្ចឹង ។

លោក **ឱក សេរី សោភក្តិ** បញ្ហារឿងអត្តសញ្ញាណប័ណ្ណ ដែលយើងបានជួបប្រទះនៅខេត្តនានា គឺបញ្ហាដែលយើងជួបប្រទះគឺប្រជាពលរដ្ឋ លោកជូនមានកន្លែងខ្លះ លោក រៀបចំបាយទឹកជូនទៅកងកំលាំងនរគលបាលដែលចុះទៅធ្វើការនេះ សឹងតែប្រជាពលរដ្ឋទូទៅនៅក្នុងព្រះរាជាណាចក្រ អោយតែផ្តល់សេវាអី អោយតែរដ្ឋបាលមូលដ្ឋានផ្តល់សេវា យើងតែងតែអោយបន្តិចបន្តួច ។

លោក គិតថា បញ្ហានេះគោង ចែកអោយដាច់អំពីការសម្លុត ឬមួយការគំរាមកំហែងយកលុយកាក់ មានកន្លែងខ្លះទៀតគាត់បានគល់បញ្ជីសនោះហើយ គាត់ទៅយក អត្តសញ្ញាណប័ណ្ណ បើសិនជាមិនអោយលុយគាត់មិនអោយទេអត្តសញ្ញាណប័ណ្ណ នោះហើយបានខុស ។ បើមានបញ្ហាហ្នឹងហើយយើងគួតែឱ្យបានឈ្មោះ ក្រុមការងារនោះចុះទៅកន្លែងណា ថ្ងៃណា ដើម្បីជូនទៅ ឯកឧត្តម ឧត្តមសេនីយ៍ឯក ហុក ឡង់ឌី ព្រោះ ឧបសែល បានធ្វើការជាមួយគាត់ ហើយគាត់បានធ្វើការស៊ើបអង្កេតរកឃើញទៅតាមរបាយការណ៍របស់យើងហើយបានដាក់ពិន័យនៅក្នុងករណីបែបហ្នឹង ។ ប៉ុន្តែអ្វីដែលជាសណ្តានចិត្តរបស់ប្រជាពលរដ្ឋ ដែលបានរៀបចំបាយទឹកជូនគាត់ យើងជូនលុយកាក់គាត់ ក្នុងការដែលគាត់ផ្តល់សេវានោះ កន្លែងណាក៏មានដែរនៅក្នុងស្រុកខ្មែរយើង ត្រង់នេះយើងអោយគាត់ហើយ តែយើងទៅចោទគាត់ថា គាត់យកលុយពីយើង លោក ថា វាមិនត្រឹមត្រូវទេ ។ ប៉ុន្តែអ្នកខ្លះទៀតមិនចាប់អារម្មណ៍ទៅធ្វើអត្តសញ្ញាណប័ណ្ណទេ ដល់ត្រូវការទៅធ្វើការនៅរោងចក្រ ចង់អោយប៉ុន្មានក៏អោយដែររួចហើយបានមកប្តឹងថា យកលុយមិនជាត្រឹមត្រូវប៉ុន្មានដែរក្នុងករណីនេះ ដូច្នេះគោងតែពេលចុះទៅធ្វើ យើងជាប្រជាពលរដ្ឋ បើដឹងដំណឹងយើងទៅធ្វើ ហើយពេលនោះគេមិនមានយកលុយពីយើងទេ ។

លោក **គង់ សារឿន** ជំទប់ទី១ ឃុំឈើទាល ស្រុកស្វាយជ្រុំ ចំពោះបញ្ហាធ្វើអត្តសញ្ញាណប័ណ្ណ តាមច្បាប់ គឺពិតជាមិនអោយយកលុយកាក់មែន ប៉ុន្តែដល់ពេលអនុវត្តន៍មែនទែន អធិការដ្ឋាននរគលបាលស្រុក គឺបានកាត់ប្រាក់ពីប៉ុស្តិ៍រដ្ឋបាលក្នុងពេលយកអត្តសញ្ញាណប័ណ្ណទៅចែកជូនប្រជាពលរដ្ឋ ហើយប៉ុស្តិ៍រដ្ឋបាលបានបន្តទៅអោយភូមិ ហើយមេភូមិបានយកលុយ ពីប្រជាពលរដ្ឋបន្តទៀត ។ ជាក់ស្តែងចំពោះអត្តសញ្ញាណប័ណ្ណដែល លោក នាំក្មួយទៅធ្វើនៅសាលាខេត្ត គឺយក៣០ដុល្លានេះជាការបន្ទាន់ លោក មិនថាទេ ដល់ទៅថតដល់កំពង់រោទាដល់ ៣៥ដុល្លា ។ ជាក់ស្តែង លោក បានទៅសួររឿងរូបថត ក្មួយដែលថតហើយស្រួលបួលហ្នឹង អោយប៉ូលិសស្រីអ្នកជួយរកថា សូមអោយជួយរកអោយក្មួយ លោក មួយប្រញាប់ទៅធ្វើការនៅរោងចក្រដែរ ប៉ូលិសស្រីហ្នឹងសួរថា តើអោយប៉ុន្មាន និងរើអោយ? នេះគឺជាការទារលុយយកចំពោះមុខតែម្តង ។

ចំពោះបញ្ហាចុះឈ្មោះលើសចំនួន និងផែនការណ៍កន្លងមក គឺដោយសារអ្នកធ្វើម្តងហើយ ធ្វើម្តងទៀត ហើយអ្នកខះមិនទាន់និងដល់អាយុផងទៅធ្វើអោយដល់អាយុ នេះហើយដែលធ្វើអោយតួលេខវាកើនលើសពីចំនួននៃ ការស្មាន។

លោក **គង់ សារូ** ប្រធានក្រុមប្រឹក្សាឃុំស្វាយរៀង ទាក់ទងនិងពេលដែលយើងចុះឈ្មោះអោយប្រជាពលរដ្ឋ យើងគិតថាកើតឆ្នាំ១៩៨៩គិតទៅដល់ថ្ងៃទី០២ខែមេសាឆ្នាំ២០០៧អាចចុះឈ្មោះបាន ។ តែដល់យើងចុះអោយ១៩៨៩នោះ មានចំនួនច្រើនដែរ ប៉ុន្តែដល់ទៅធ្វើអត្តសញ្ញាណប័ណ្ណមិនអោយធ្វើទេ ។ លោក សូមអោយជួយធ្វើការបំភ្លឺនៅក្នុងរឿងនេះ ។ តាមគំនិត លោក អ្នកកើតឆ្នាំ ១៩៨៩ ដែលយើងចុះអោយគាត់ហើយតែមិនបានធ្វើអត្តសញ្ញាណប័ណ្ណ នោះការបោះឆ្នោតត្រូវបាត់សំលេង ។

លោក **មេច ឌួក** សមាជិកក្រុមប្រឹក្សាឃុំចំបក់ ទាក់ទងនិងការចែកប័ណ្ណពតិមានឃើញថា ភាគច្រើនត្រូវហើយក៏ប៉ុន្តែនៅសល់មួយចំនួនដែលរកឈ្មោះមិនឃើញ មិនស្គាល់ឈ្មោះ ហើយអ្នកដែលផ្លាស់ទីលំនៅក៏នៅមានដែរ នៅពេលនោះ លោក សួរទៅស្មៀនថា គួរតែលុបឬមួយយ៉ាងណា បើមនុស្សនោះចេញពីរបីឆ្នាំហើយ គាត់ថាទាល់តែមានមេភូមិធ្វើរបាយការណ៍ឡើងមកបានគាត់លុបបាន ។ លោក សូមសួរថា ដល់ពេលបិតបញ្ជីចុងក្រោយឈ្មោះនោះយើងមើលឃើញថា នៅតែមានឈ្មោះហើយរកមិនឃើញ តើគួរមានវិធានការណ៍យ៉ាងណា ? ហើយទាក់ទងទៅនិងព្រះសង្ឃ តើព្រះសង្ឃអាចធ្វើនយោបាយបានដែរឬទេ ?

ព្រះតេជគុណ **អ៊ុក សារី** វត្តព្រៃឆ្លាក់ បានលើកឡើងទាក់ទងថាហេតុអ្វីបានជាអោយព្រះសង្ឃបោះឆ្នោត ? ព្រោះអាណត្តិមុនៗនោះ គឺព្រះសង្ឃមិនមានការបោះឆ្នោតទេ គឺព្រះសង្ឃជាអព្យាក្រឹត្យភាព ភាពគ្មានលំអៀងទៅកាន់គណបក្សណាមួយឡើយ ។ បើសិនជាព្រះសង្ឃមានសិទ្ធបោះឆ្នោត អាត្មាយល់ថា អាចមានការឈានទៅរកការបែកបាក់សង្ឃនៅតាមវត្តមួយចំនួន ព្រោះបើព្រះសង្ឃ មានសិទ្ធបោះឆ្នោត ព្រះសង្ឃមានសិទ្ធជ្រើសរើសហើយ ឧទាហរណ៍ថា វត្តមួយៗមានព្រះចៅអធិការវត្ត មានគ្រូសូត្រឆ្វេងស្តាំ និងភិក្ខុសាមណេរ អញ្ចឹងព្រះចៅអធិការ លោក មានសិទ្ធជ្រើសរើសគណបក្សណាមួយទៅ ហើយគ្រូសូត្រស្តាំចូលគណបក្សណាមួយអញ្ចឹងទៅ ហើយការ និយាយ បញ្ចុះបញ្ចូលពុទ្ធបរិសាទអោយមកជឿជាក់ខាងខ្លួនអញ្ចឹងទៅ អាត្មាយល់ថា អាចមានបញ្ហាកើតមានឡើងបាននៅក្នុងវត្ត ។

ព្រះតេជគុណ **ទីវ សុភា** គ្រូបង្រៀននៅពុទ្ធិកៈវិទ្យាល័យស្វាយរៀង ការដែលអោយព្រះសង្ឃចូលរួមនៅក្នុងការបោះឆ្នោតអាចធ្វើអោយមានការបែកបាក់សាមគ្គីរវាងសង្ឃ វាជាបញ្ហាមួយដែលប៉ះពាល់ដល់និរន្តរ៍ភាពនៃព្រះពុទ្ធសាសនា ។ នៅក្នុងរដ្ឋធម្មនុញ្ញបានចែងថា ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ កាលណាកំណត់ថា អោយព្រះសង្ឃអាចបោះឆ្នោតមានន័យថា ជាការចូលរួមក្នុងការបំផ្លាញព្រះពុទ្ធសាសនា ព្រោះកាលណា ព្រះសង្ឃចូលរួមនៅក្នុងការបោះឆ្នោត គឺលោកប្រាស់ចាកនូវអគតិទាំង៤ គឺ ឆន្ទា ទោសៈ វិវាទ និងមោហៈ កាលណាប្រាស់ចាកនូវ អគតិនេះ ហើយធ្វើអោយមានវិបត្តិខ្លាំងនៅក្នុងសង្គមសង្ឃ ។ ហើយអាត្មាជឿថា គ្រប់គណបក្សទាំងអស់សុទ្ធតែកាន់នូវព្រះពុទ្ធសាសនា បើអោយព្រះសង្ឃទៅធ្វើការជ្រើសរើសបានន័យថា តើត្រូវចោលខាងណាទុកខាងណា? ហើយចំពោះបុគ្គលដែលព្រះសង្ឃជ្រើសរើស នោះគេនិងពេញចិត្ត តែចំពោះអ្នកដទៃដែលមិនបានជ្រើសរើសនោះតើគេគិតយ៉ាងម៉េច? ដូច្នេះអាត្មាគិតថា ការចេញច្បាប់អោយព្រះសង្ឃបោះឆ្នោតនោះ និរន្តរ៍ភាពនៃព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋដែលជាសាសនានៃប្រជាជាតិកម្ពុជា និងបាត់បង់ចេញពីទឹកដីខ្មែរ និងសណ្តានចិត្តខ្មែរ ដូច្នេះសូមអោយធ្វើការពិចារណាច្បាប់នេះសារជាថ្មី ។

លោក **ឱក សេរី សោភក្តិ៍** សង្គមកម្ពុជាគួរតែមានការពិភាក្សាមួយស៊ីជំរៅអំពីតួនាទីរបស់ព្រះសង្ឃនៅក្នុងសង្គម ។ លោក គិតថា ប្រហែលជាអាចរៀបចំការជជែកពិភាក្សាមួយនៅក្នុងការស្រាវជ្រាវថា តើព្រះសង្ឃគួរតែធ្វើយ៉ាងណា? យើង យកអត្ថបទរបស់រដ្ឋធម្មនុញ្ញយកមកពិនិត្យមើល ហើយខេត្តឯទៀតៗ សកលវិទ្យាល័យឯទៀតៗ នៅភ្នំពេញក៏គួរតែធ្វើការពិភាក្សាអោយបានស៊ីជំរៅដែរ បើសិនជាបានរបាយការណ៍សរុបមកចាំយើងយកទៅជូនគណៈសង្ឃ ទាំង២ ក្រសួងធម្មការ និងរាជរដ្ឋាភិបាលថា តើយើងគួរ

ដូរ ឬមួយបន្ថែមធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញរបស់យើងយ៉ាងណា? ព្រោះ លោក ឯកភាពពេញទីថា តែកាលណាមានសិទ្ធបោះឆ្នោត ត្រូវតែមានសិទ្ធជ្រើសរើស តែកាលណាមានសិទ្ធជ្រើសរើសត្រូវតែមានសិទ្ធធ្វើការពិចារណា តែកាលណាមានការពិចារណា ទេសនាក៏ទៅតាមហ្នឹងដែរ ។ ដូច្នេះវាមានពាក់ព័ន្ធទៅនិងអ្វីៗទាំងអស់ ដូចជាក្នុងវត្តអារាម ការជ្រើសរើសរបស់ព្រះសង្ឃពាក្យទេសនាផ្សេងៗ ។

លោក **ខៀវ សុខុម** ស្នងការនគរបាលខេត្តស្វាយរៀង ពាក់ព័ន្ធនិងការផ្តល់អត្តសញ្ញាណប័ណ្ណ ។

បញ្ហាទី១ ទាក់ទងទៅនិងជំទប់ទី១ឃុំឈើទាល ដែលបានលើកឡើងថា អធិការដ្ឋាននគរបាលស្រុក គឺបានកាត់ប្រាក់ពីប៉ុស្តិ៍រដ្ឋបាលក្នុងពេលយកអត្តសញ្ញាណប័ណ្ណទៅចែកជូនប្រជាពលរដ្ឋ ហើយប៉ុស្តិ៍រដ្ឋបាលបានបន្តទៅអោយភូមិ ហើយមេភូមិបានយកលុយពីប្រជាពលរដ្ឋបន្តទៀត ។ ចំពោះបញ្ហានេះ កន្លងមកខាង លោក ក៏មិនទាន់មានទទួលរបាយការណ៍ឬក៏ពាក្យបណ្តឹងជុំវិញបញ្ហានេះដែរ ទើបតែបានឮនៅពេលនេះ លោក នឹងរាយការណ៍ជូនលោកស្នងការហើយនឹងមានវិធានការណ៍ចុះស៊ើបករណីនេះនៅក្នុងឃុំឈើទាល ។ ហើយ លោក ក៏សូមអោយធ្វើការកត់ត្រាអោយបានច្បាស់នូវពាក្យបណ្តឹងនេះ ដើម្បីអោយ លោក មានមូលដ្ឋានច្បាស់ ដើម្បីបញ្ជូនទៅលោកស្នងការ ហើយលោកស្នងការនឹងចាត់បញ្ជូនមន្ត្រីចុះទៅស៊ើបអង្កេតបញ្ជាក់នៅលើបញ្ហានេះ ។ បញ្ហាទី២ ការផ្តល់អត្តសញ្ញាណប័ណ្ណដល់ប្រជាពលរដ្ឋដែលមិនទាន់គ្រប់អាយុ គឺកន្លងមកនេះក្រុមជំនាញរបស់លោកបានធ្វើការឯកភាពជាមួយ គខប ។ ការធ្វើនេះអត់បានឯកភាពដោយ គខប បានកំណត់ថា ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៧ ចាប់ពីពេលនេះទៅនឹងផ្តល់អត្តសញ្ញាណប័ណ្ណជូន ។ ការផ្តល់នេះមានចំនួនតិចតួចទេ គឺបានយកអត្តសញ្ញាណប័ណ្ណនេះទៅអោយ ឯកឧត្តម ចុះហត្ថលេខា ក៏ប៉ុន្តែដោយឯកឧត្តមអភិបាលខេត្តគាត់ពិនិត្យមើលឃើញមានខ្វះមិនគ្រប់អាយុ គាត់មិនបានចុះហត្ថលេខាទេ ហើយអត្តសញ្ញាណប័ណ្ណនេះ គឺទុកនៅសាលាខេត្ត ដើម្បីនឹងធ្វើការពិនិត្យមើលឡើងវិញ ។

លោក **សូរ្យ ទិត្យ** បានធ្វើការបញ្ជាក់ចំពោះចំលើយ លោក ក្រុមប្រឹក្សាឃុំស្វាយរៀង ដែលលើកឡើងថា នៅថ្ងៃបោះឆ្នោត ថ្ងៃទី ០១ ខែ មេសា ឆ្នាំ២០០៧ នេះ អ្នកដែលខ្វះអាយុទៅធ្វើអត្តសញ្ញាណប័ណ្ណអត់បានទេ ព្រោះគោលការណ៍អត្តសញ្ញាណប័ណ្ណតាម លោក ក្តាប់បានគិត ១៨ឆ្នាំ ដល់ថ្ងៃធ្វើ ប៉ុន្តែដល់ការងារបោះឆ្នោតយើងគិតដល់ថ្ងៃបោះឆ្នោត ហើយដំណោះស្រាយយើងអាចរកបានមិនពិបាកទេ បើកាលណាអត្តសញ្ញាណប័ណ្ណលោកចេញមិនកើត យើងប្រើ១០១៨ ដោយមានបិតរូបថត គាត់មិនអាចខ្វះរូបថតបានទេ ព្រោះ១០១៨ ដែលអាចបោះឆ្នោតបានលុះត្រាតែមានរូបថត ។ បញ្ហារឿងប្រជាពលរដ្ឋផ្លាស់ចេញដោយគ្មានទីលំនៅអន្ត្រៃយ៍នោះជាភារៈកិច្ចរបស់មេឃុំ តាមរបាយការណ៍របស់ភូមិ មានបញ្ជាក់របស់ឃុំពីការគ្មានលំនៅអន្ត្រៃយ៍នោះយើងអាចលុបចេញបានហើយ ។ លោក ជឿថា នៅពេលបោះឆ្នោតបញ្ជីនឹងប៉ោង ព្រោះតែគាត់មិនបានលុបដោយខ្លះគាត់ថា ប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោតច្រើន ដូច្នេះគាត់ មិនមានពេលសម្រាប់ធ្វើទំរង់បែបបទលុបមិនបាន ព្រោះកាលលុបនេះយើងត្រូវធ្វើទំរង់បែបបទលុបអោយបានច្បាស់លាស់ ។

ចំពោះរឿងព្រះសង្ឃចូលរួមនៅក្នុងការបោះឆ្នោតនេះ វាមិនមែនជាសមត្ថកិច្ចរបស់ លោក ទេ រឿងនេះជារឿងថ្នាក់ជាតិ ត្រូវពិភាក្សាគ្នាដោះស្រាយយ៉ាងណា? ដើម្បីអោយសាសនាយើងនៅគង់វង្ស ហើយជាទីគោរពបូជារបស់ប្រជាពលរដ្ឋយើង ។

លោក **ឱក សេរីសោភក្តិ** ហេតុផលដែលខាងនគរបាលមិនអាចចេញជូនបាននៅពេលដែលមានអាយុគ្រប់១៨ ព្រោះប័ណ្ណនេះសំគាល់ថា យើងចូលដល់គ្រប់វ័យអាយុហើយចំពោះមុខថ្នាក់ជាតិ ដូច្នេះហើយបើមានទោសរដ្ឋប្បវេណីក្តី ទោសព្រហ្មទណ្ឌក្តី ការផ្តល់ទានទោសហ្នឹង គឺមានក៏រិត អញ្ចឹងបើចាប់តាំងពីពេលនេះរហូតដល់ថ្ងៃ០១ មេសា មានធ្វើទោស ហើយអ្នកហ្នឹងមិនទាន់ដល់គ្រប់អាយុ អាចនឹងមានបញ្ហាចំពោះមុខច្បាប់ ។ អញ្ចឹងហើយបានជាខាងនគរបាលបានមិនអាចចេញអោយបានមុន ១៨ឆ្នាំ ព្រោះវាទាក់

ទងទៅនិងបញ្ហាច្បាប់ ហើយច្បាប់បោះឆ្នោតមិនទាក់ទងទៅនិងច្បាប់ទាំងនេះទេ ទើបបានជា គជប អនុញ្ញាតិអោយបោះឆ្នោតបាន អោយធ្វើសំបុត្រដើម្បីបោះឆ្នោតបាន ។

លោក **វ៉ាន់ ប៊ុនធឿន** នាយកប្រតិបត្តិអង្គការ SADA បញ្ហាជំទាស់របស់គណបក្ស ទាក់ទងនិងការចុះឈ្មោះមានជនជាតិវៀតណាមគាត់ចូលចុះឈ្មោះដែរ ។ បើពិនិត្យមើលរដ្ឋធម្មនុញ្ញ គឺមានតែព្រះមហាក្សត្រមួយគត់ដែលអាច អោយជនបរទេសចុះចូលជាសញ្ជាតិ ហើយនៅពេលចូលជាសញ្ជាតិហើយទើបមានសិទ្ធបោះឆ្នោត ។ តើការពិនិត្យអត្រានុកូលដ្ឋាន ឬការចុះឈ្មោះនៅក្នុងឃុំហ្នឹងយ៉ាងម៉េច បានជាច្រឡំអោយមានជនជាតិវៀតណាមអាចចុះឈ្មោះបាន? ហើយអោយមានអ្នកជំទាស់ប្តឹង គជប អញ្ចឹង? តើមានវិធីសាស្រ្តអ្វីខ្លះដើម្បីជៀសវាងកុំអោយបរទេសមកចុះឈ្មោះធ្វើអត្តសញ្ញាណប័ណ្ណ ព្រោះតាមរយៈការជជែកគ្នាទៅឃើញថា ការបោះឆ្នោតអោយតែមានអត្តសញ្ញាណប័ណ្ណជាសញ្ជាតិខ្មែរមានសិទ្ធចុះឈ្មោះបោះឆ្នោតហើយ ។ តើ គជប គួរមាននីតិវិធីយ៉ាងណាដើម្បីចុះទៅពិនិត្យមើលថា តើអ្នកហ្នឹងជាជនបរទេសមែន ឬគាត់បានចូលមកសញ្ជាតិខ្មែរដោយយ៉ាងម៉េច? ហើយ លោក បានឮដែរខាងខមប្រែ្វល លោក គល់ បញ្ញា ថា អោយតែអ្នកនោះមកតាំងពី ៧៩មក ដល់ឥឡូវគ្រប់យូរឆ្នាំហើយ អញ្ចឹងគាត់ជាជនជាតិភាគតិចអញ្ចឹងគាត់មានសិទ្ធចូលបោះឆ្នោតហើយ ។ លោក ចង់អោយបញ្ជាក់ត្រង់នេះអោយច្បាស់ដើម្បីកុំអាយ ខាងគណបក្សនយោបាយគាត់មានមន្ទិលពាក់ព័ន្ធនិងរឿងហ្នឹងទៀត លោក ចង់សួរថា តើប្រជាពលរដ្ឋដែលចូលមកប្រទេសខ្មែរហើយមិនទាន់បានចូលសញ្ជាតិដែលចុះហត្ថលេខាដោយព្រះមហាក្សត្រស្រាបន់តែគាត់មានសិទ្ធបោះឆ្នោតតើយ៉ាងម៉េចដែរ?

លោក **ឱក សេរី សោភក្តិ៍** ទាក់ទងនិងច្បាប់ជនអន្តោប្រវេសន្តនេះយើងមានច្បាប់២ គឺច្បាប់អន្តោប្រវេសន្តមួយ និងច្បាប់សញ្ជាតិខ្មែរមួយ ។ ច្បាប់ហ្នឹងនិយាយច្បាស់ណាស់ថា អន្តោប្រវេសន្តដែលចូលមកនៅយូរហើយ ទោះអ្នកនោះជាជនជាតិដើមវៀតណាម ឬមួយអាមេរិកក៏ដោយ ។ ជាក់ស្តែងអ្នកស្រីអេវ៉ា ដែលគាត់ជាប្រធានអង្គការ CDRI មុន គាត់ជាជនជាតិអាមេរិកពីដើមហើយគាត់បានចូលសញ្ជាតិខ្មែរ របស់យើងទៅតាមច្បាប់សញ្ជាតិ ដែលចុះហត្ថលេខាដោយព្រះមហាក្សត្រត្រឹមត្រូវ នេះបានហៅថាចូលសញ្ជាតិស្របច្បាប់មែន ហើយអាចមានសិទ្ធមានកាតមានអត្តសញ្ញាណប័ណ្ណច្បាស់លាស់មែន មានតែវិធីនេះទេដែលអន្តោប្រវេសន្តអាចមានសិទ្ធក្លាយទៅជាជនជាតិខ្មែរពិតប្រាកដ ។ លោក បានបន្តថា នៅភ្នំពេញក៏មាន នៅកន្លែងណាទៀតក៏មានដែរជនជាតិបរទេសដែលគ្រាន់តែយកលុយទៅទិញទៅ កន្លែងខ្លះអាចធ្វើបាន នេះតាម លោក ដឹងនិងឃើញ ។ បញ្ហានេះពិបាកនឹងទប់ស្កាត់ណាស់ព្រោះវាទាក់ទងទៅនិងអភិបាលកិច្ចនៅថ្នាក់មូលដ្ឋាន ព្រោះរដ្ឋាភិបាលមិនអាចមានភ្នែកគ្រប់ទីកន្លែងទៅចាំមើលបានទេ ។ ដូច្នេះអ្វីដែលធ្វើខុសពីច្បាប់ដែលមានចែងនៅក្នុងច្បាប់សញ្ជាតិ គឺសុទ្ធតែខុសច្បាប់ទាំងអស់ ប៉ុន្តែបើគាត់ទទួលបានអត្តសញ្ញាណប័ណ្ណដោយប្រការណាមួយនោះ គជប មិនមានសិទ្ធអីហាមឃាត់គាត់ទេ ទោះគាត់មិនចេះនិយាយភាសារខ្មែរក៏ដោយ អោយតែគាត់មានអត្តសញ្ញាណប័ណ្ណ គជប គ្រាន់តែដឹងថា បើកាលណាគេមានអត្តសញ្ញាណប័ណ្ណត្រូវតែចុះអោយគេហើយ ។ តោងតែទទួលស្គាល់ទាំងអស់គ្នាថា ប្រទេសរបស់យើងនៅមានការខ្វះចន្លោះនោក្នុងការគ្រប់គ្រងសញ្ជាតិនិងអត្តសញ្ញាណប័ណ្ណនេះឯង អ្វីដែលអស់លោកលើកឡើងជាការត្រឹមត្រូវណាស់ មានតែយើងជួយគ្នាអញ្ចឹងទេ បើសិនយើងឃើញករណីហ្នឹង យើងលើកអោយច្បាស់ថា ភូមិហ្នឹងឈ្មោះអី អាជ្ញាធរគាត់អ្នកចេញអោយឈ្មោះអី ហើយយើងធ្វើការស៊ើបអង្កេតទាំងអស់គ្នា យើងផ្តល់ដំណឹងនេះទៅថ្នាក់លើទៅព្រោះយើងធ្លាប់បានធ្វើហើយគេដកសញ្ជាតិដែលផ្តល់អោយខុសច្បាប់ហ្នឹង ដកមកវិញបានខ្លះហើយ មានតែយើងធ្វើអោយតម្លាភាពអញ្ចឹងទេ ទើបអាចទប់ស្កាត់អំពើហ្នឹងទៅថ្ងៃក្រោយបាន ។

លោកស្រី **ចាន់ ផល្លី** សមាជិកក្រុមប្រឹក្សាឃុំកំពង់រោទិ៍ គណបក្សប្រជាជន បានពិនិត្យមើលទៅលើតំរូវការរបស់ប្រជាពលរដ្ឋពីតំបូងពីឆ្នាំ ១៩៩៨មក គឺយើងបោះឆ្នោតទៅតាមកាត ហើយពេលនេះដែលយើងបោះនៅថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៧ នេះ

គឺបោះតំរូវនិង អត្តសញ្ញាណប័ណ្ណ អញ្ចឹងការបោះឆ្នោតតំរូវតាមនេះ ប្រជាពលរដ្ឋយើងមកពិនិត្យបញ្ជីឈ្មោះ និងកែតំរូវឈ្មោះនេះ គឺបានច្រើនហើយ ប៉ុន្តែនៅមានប្រជាពលរដ្ឋខ្លះគាត់មិនទាន់យល់ពីភារៈកិច្ចជាប្រជាពលរដ្ឋរបស់គាត់ បញ្ហានេះ លោកស្រីមានការបារម្ភខ្លាំងណាស់ ដែល គាត់មិនបានមកធ្វើការកែតំរូវអក្ខរាវិរុទ្ធឈ្មោះរបស់គាត់ និងថ្ងៃខែឆ្នាំរបស់គាត់ ។ លោកស្រី សូមអោយលោកប្រធាន PEC ធ្វើការ ពិនិត្យពិចារណាឡើងវិញ ។

លោក **សំ រតនា** គណបក្ស សម រង្ស៊ី ទាក់ទងនិងភាពមិនប្រក្រតីនៅក្នុងឃុំរបស់លោក ដែលស្មៀនឃុំជាអ្នកចុះឈ្មោះបំរើការងារអោយ គជប ប៉ុន្តែស្មៀនគាត់មិនបានបំពេញតួនាទីអោយបានច្បាស់ទៅតាមផ្លូវច្បាប់ទេ គាត់សម្លឹងមើលថា ប្រជាពលរដ្ឋណាមួយនៅក្នុងភូមិរបស់គាត់ដែលគាត់ថា អ្នកហ្នឹងមាននិន្នាការទៅរកនយោបាយគណបក្សណាមួយដែលគាត់មិនពេញចិត្ត គាត់សួររកមូលហេតុ ឯកសាររបស់គាត់មិនចេះចប់មិនចេះហើយ ឧទាហរណ៏ ដូចជាមានសៀវភៅគ្រួសារហើយ គាត់យកទៅអោយស្មៀនឃុំចុះ គាត់សួររកសំបុត្រកំណើតទៀត ។ តាមពិតសៀវភៅគ្រួសារក៏ចុះឈ្មោះអោយបានដែរ តែគាត់មិនព្រមចុះ ។ ពេលនោះខាងតំណាងគណបក្សនយោបាយ លោក បានតវ៉ានៅក្នុងពេលចុះឈ្មោះហ្នឹងគាត់មិនព្រមធ្វើអោយទេ ហើយ លោក ក៏សុំ១០១៨ ដោយសារមិនមានអត្តសញ្ញាណប័ណ្ណ តែស្មៀនមិនចេញអោយទេ គាត់ទៅចេញបង្កាន់ដៃអោយទៅវិញ ហើយថាបង្កាន់ដៃនេះហើយដែលអាចបោះឆ្នោតបាន ។ ប្រជាពលរដ្ឋគាត់ធុញគាត់ ក៏ត្រឡប់ទៅផ្ទះវិញទៅ ហើយបើប្រជាពលរដ្ឋណាដែលមាននិន្នាការទៅរកគណបក្សនយោបាយដែលខ្លួនគាត់ពេញចិត្ត គាត់ប្រញាប់ទទួលដោយរាក់ទាក់គ្មានសួរមូលហេតុអ្វីទេចុះដោយទូលាយ ។ ទាក់ទងនិងការបង្កើនអាយុអោយដល់អាយុ ១៨ឆ្នាំ នៅថ្ងៃបោះឆ្នោតថ្ងៃ០១ ខែមេសា ឆ្នាំ២០០៧ ពីមុនមកមន្ត្រីអត្រានុកូលដ្ឋានគាត់មានការកំណត់បញ្ឈប់ការចុះឈ្មោះហ្នឹង តែដល់ពេលជិតរៀបចំការបោះឆ្នោត គាត់មានកម្មវិធីចុះសំបុត្រកំណើត ហើយក្រដាសដែលចុះនោះនៅថ្មីដែល ប្រជាពលរដ្ឋគាត់យកមកចុះឈ្មោះបោះឆ្នោតបន្ថែមដោយដឹងថា អ្នកហ្នឹងបោះឆ្នោតអោយខ្លួន ។ មានស្មៀនឃុំខ្លះក្នុងឱកាសដែល កំពុងតែចុះឈ្មោះថ្ងៃ ២១ ស្មៀនឃុំយង់ គាត់ធ្វើតែព្រឹក ឈប់ល្ងាច នាំគ្នាទៅញ៉ាំស្រានៅប៉ុស្តិ៍នៅព្រំដែន អត់ធ្វើការទេ ហើយថ្ងៃ២២ គាត់ធ្វើព្រឹកឈប់ល្ងាចទៀត ពីរថ្ងៃជាប់គ្នា ។ ហើយថ្ងៃ១៩ តុលា មេឃុំញ៉ាំស្រាស្រវឹង ជិះម៉ូតូបំណងបុកភ្នាក់ងារគណបក្សនយោបាយដែលគាត់មានគំនុំ ឬដោយអាងនយោបាយ ។ នៅឃុំស្វាយទាលក៏អញ្ចឹងដែរ នៅ៤ថ្ងៃចុះក្រោយនេះមកអើតមើលមួយភ្លែត ហើយនាំគ្នាទៅញ៉ាំស្រាមិនមកធ្វើការទេ ឯភូមិសាមគ្គី មេភូមិឡើងអង្គុយនៅលើតុតែម្តង នៅពេលដែលស្មៀនឃុំកំពុងតែចុះឈ្មោះបោះឆ្នោត ហើយទៅយកប័ណ្ណពតិមានអ្នកបោះឆ្នោត សៀវភៅគ្រួសារ គាត់យកទៅពិនិត្យជំនួសស្មៀនទៅទៀត ដេញអោយចុះមិនចុះ ហើយគាត់ញ៉ាំស្រាទៀត ។ សំនូមពរថា កុំ អោយមានការរំខានដល់បរិយាកាសនៃការចុះឈ្មោះរបស់ស្មៀនឃុំ និងគណៈកម្មាធិការទៀត ។

លោក **ស៊ុំ ម៉ារ៉ា** មកពីឃុំចំបក់ គណបក្ស សមរង្ស៊ី ទាក់ទងនិងការរាប់សន្លឹកឆ្នោតនេះសម្រាប់ផ្លូវច្បាប់ និងក្របខណ្ឌមួយការិយាល័យត្រូវភ្នាក់ងាររបស់គណបក្សនយោបាយ ឬភ្នាក់ងារជាតិហ្នឹងតំណាងទៅបានតែមួយរូបទេ ប្រសិនបើមួយរូប មួយការិយាល័យរាប់តែតុ១ នោះយើងម្នាក់ដែលមើលនៅក្នុងនោះមើលសព្វ តែបើការិយាល័យហ្នឹងតុរាប់ដល់ទៅ២-៣តុ ជាសំនូមពររបស់ លោក បើមានរាប់២-៣តុនោះ សូមអោយតំណាងគណបក្សនយោបាយ ឬភ្នាក់ងារជាតិហ្នឹងតំណាងទៅបាន១តុម្នាក់ចុះ នេះបើរាប់ច្រើន យើងចង់អោយពេលវេលាអោយលឿន ។ ហើយបញ្ហាចេញលទ្ធផលបណ្តោះអាសន្នរបស់ គជប នៅថ្នាក់ឃុំ សូមអោយ គជប ចេញនៅពេលរាប់ លទ្ធផលភ្លាម និងសូមអោយឃុំនៅការិយាល័យហ្នឹងចេញលទ្ធផលដែលបោះឆ្នោតបណ្តោះអាសន្ន អោយទៅភ្នាក់ងារសង្កេតការណ៏ទាំងអស់នៅល្ងាចហ្នឹង កុំទុកចាំស្អែក ឬ១-៣ថ្ងៃនោះ ព្រោះទី១ ដើម្បីអោយអ្នកឈ្នះ ឈ្នះដោយយុត្តិធមិ ហើយអ្នកចាញ់ គឺចាញ់ដោយអស់ចិត្ត ។

លោកស្រី **គីម ស៊ុនណារី** មេឃុំ រមាសហែក គណបក្សប្រជាជនកម្ពុជា មានចំងល់ថា ប្រជាពលរដ្ឋយើងគាត់ធ្វើចសំណាក ស្រុក ហើយគាត់មានការយឺតយ៉ាវក្នុងការមកពិនិត្យបញ្ជីឈ្មោះ និងការកែតំរូវបញ្ជីឈ្មោះហ្នឹង លោកស្រី សូមសួរថា ក្នុងការកែតំរូវ បញ្ជីឈ្មោះបន្ទាន់នេះ បើមានខុសអក្ខរាឈ្មោះបន្តិចបន្តួច ឧទាហរណ៍ដូចជាគាត់ឈ្មោះ សុខ ចំរើនអញ្ចឹងទៅ ដោយ សុខ មានសរសេរ សុខ និង ខ ឬសុក និងក អញ្ចឹងវាខុសអក្ខរាវិរុទ្ធបន្តិចបន្តួច ប៉ុន្តែគាត់មកកែតំរូវមិនទាន់ ហើយជាពិសេសថ្ងៃខែឆ្នាំកំណើតនេះឯង ព្រោះ លោកស្រី ចុះធ្វើផ្ទាល់ថ្ងៃខែឆ្នាំកំណើត ជួនកាលត្រូវខែ ត្រូវថ្ងៃ ខុសឆ្នាំ ជួនកាលត្រូវឆ្នាំ ត្រូវខែ ខុសថ្ងៃ អញ្ចឹងក្នុងករណីខុស បន្តិចបន្តួចនេះ តើគួរអនុគ្រោះអោយគាត់បោះឆ្នោតបានដែរឬទេ?

លោក **ភោគ ឈន** ទាក់ទងនិងបញ្ហាទំនាស់នៅក្នុងពេលបោះឆ្នោតខាងមុខនេះ អោយតែពេលបោះឆ្នោត គឺមានទំនាស់ហើយ ឧបមាថា ទំនាស់នោះជាទំនាស់នយោបាយ ហើយដល់ផុតពីការបោះឆ្នោតហើយលែងមានទំនាស់ហើយ អញ្ចឹង លោក សូមសួរលោក ប្រធាន PEC ថា តើមានវិធីសាស្ត្រយ៉ាងណាដើម្បីកុំអោយមានទំនាស់នៅក្នុងពេលបោះឆ្នោតនៅក្នុងថ្ងៃខាងមុខ ?

លោក **ឱក សេ រីសោភក្តិ៍** អ្វីដែលបានលើកឡើងមកនេះ គឺ ឧប់សែល កំពុងតែធ្វើនេះហើយ គឺការជួបប្រជុំគ្នា លើកយកនូវ បញ្ហានិងដំណោះស្រាយយកមកដក់នៅលើតុដើម្បីជជែកពិភាក្សាគ្នារកដំណោះស្រាយ ហើយរឿងនេះយើងត្រូវការពេលវេលា យើង ច្បាំងគ្នា២៨ឆ្នាំ យើងមានសន្តិភាពពិតប្រាកដតែ ៨ឆ្នាំ មកទេ ពី១៩៩៨ដែលតាម៉ុកគាត់ចូលមកចុងក្រោយគេ ដូច្នេះ ៨ឆ្នាំ យើង កសាងបានប៉ុណ្ណឹងយើងគួរមានមោទនភាពណាស់ យើងច្បាំងគ្នាហើយ យើងមកអង្គុយនិយាយគ្នាដូចថ្ងៃនេះជាដើម ។

លោក **ពោជ ម៉ាន់** តំណាងអោយគណបក្សហ៊្វុនស៊ិនប៉ិច ពាក់ពន្ធ័និងការខ្វះខាតបច្ចេកទេសនៅលើអត្តសញ្ញាណប័ណ្ណ ដោយ អត្តសញ្ញាណប័ណ្ណផ្តល់ជូនប្រជាពលរដ្ឋហើយតែវាមានលក្ខណ:ខុសឆ្គង ខុសត្រង់ថាមនុស្សហ្នឹង ភេទប្រុស ដល់ចុះដាក់ភេទស្រី ហើយឆ្នាំកំណើត ឧទាហរណ៍ថា ឆ្នាំ១៩៥០ ដាក់១៥០ ។ តើលក្ខណ:ខុសឆ្គងនេះអាចបោះឆ្នោតបានដែរឬអត់ ?

លោក **ម៉ៅ នាង** ក្រុមប្រឹក្សាឃុំចំបក់ គណបក្ស សម រង្ស៊ី ទាក់ទងនិងការរារាំងទៅលើការឃោសនាឆ្នាំ២០០៧ តើគណៈកម្មាធិការរៀបចំការ បោះឆ្នោតមានវិធានការណ៍យ៉ាងណាទៅលើអ្នករារាំងទៅលើការឃោសនា? ហើយការរារាំងទៅលើ សមាជិកគណបក្សនយោបាយក្នុងឆ្នាំ២០០៧នេះ តើគណៈកម្មាធិការរៀបចំការបោះឆ្នោតមានវិធានការណ៍យ៉ាងណា? តើបញ្ហាការ រាប់សន្លឹកឆ្នោតតើគណៈកម្មាធិការរៀបចំការបោះឆ្នោតមានវិធានការណ៍យ៉ាងណានៅលើបញ្ហានេះ? ហើយចំនុចមួយទៀតនៅឃុំ របស់លោក គឺលោកទាន់ច្បាស់ លាស់ អ៊ុំ សាន មានពីរនាក់ មួយអាយុ៣០ មួយទៀតអាយុ៦០ឆ្នាំ ដល់អ៊ុំសានអាយុ៣០គាត់ទៅបោះ ហើយដល់អ៊ុំ សានអាយុ ៦០ទៅបោះ គេថាអ៊ុំឯងមិនមែនអាយុ៣០ទេ អ៊ីឯងអាយុ៦០ហើយ តែអ៊ុំសានដែលអាយុ៣០បោះមុននោះ បោះរួចហើយ ដល់មកតវ៉ា លោក មិនដឹងថាម៉េចទេ ព្រោះគេបោះបាត់ទៅហើយ បញ្ហានេះសូមអោយលោកប្រធានរើសប្រធាន ការិយាល័យអោយពិនិត្យអោយ ច្បាស់លាស់ផង ។

លោក **ខៀវ សុខុម** ឆ្លើយបំភ្លឺចំពោះការផ្តល់អត្តសញ្ញាណប័ណ្ណ លោកបានបញ្ជាក់ថា ការផ្តល់អត្តសញ្ញាណប័ណ្ណចំពោះលោក ប៊ុន ធឿន ដែលថា ការផ្តល់ គឺបានអោយទៅជនជាតិវៀតណាមដែលជាជនបរទេស ។ តាមការពិនិត្យ និងការអនុវត្តកន្លងមកក្រុម ជំនាញខាង លោក មិនបានផ្តល់អត្តសញ្ញាណប័ណ្ណជូនជនបរទេស ទេជាពិសេសជនជាតិវៀតណាមដែលចូលមកនៅក្នុងស្រុកខ្មែរដោយ បែបអន្តោប្រវេសន្តខុសច្បាប់នោះទេ ។ រាល់ការផ្តល់អត្តសញ្ញាណប័ណ្ណអោយជនជាតិវៀតណាម លុះត្រាតែមានឯកសារច្បាស់លាស់ ថា គាត់គឺនៅស្រុកខ្មែរយូរហើយគាត់មានកាតតាំងពីជំនាន់រាជានិយម ដូច្នេះទាល់តែមានឯកសារច្បាស់លាស់បានផ្តល់អត្តសញ្ញាណ ប័ណ្ណអោយគាត់ ។ បើសិនជាមានផ្តល់អោយជនជាតិវៀតណាម លោក សូមអោយចង្អុលបង្ហាញជនជាតិវៀតណាមដែលបានទទួល អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលក្រុមជំនាញខាង លោក ផ្តល់ជូនខុសងច្បាប់នេះ សូមបង្ហាញជូនអោយច្បាស់លាស់ ខាងលោក

នឹងធ្វើការាយការណ៍ជូនលោកស្នងការដើម្បីចុះត្រួតពិនិត្យបញ្ជាក់ចំពោះមុខសញ្ញាដែលទទួលបានអត្តសញ្ញាណប័ណ្ណដោយ ខុសច្បាប់នេះ ។ ចំពោះការផ្តល់អត្តសញ្ញាណប័ណ្ណដោយមានកំហុសឆ្គង លោក ទទួលស្គាល់ព្រោះការផ្តល់អត្តសញ្ញាណប័ណ្ណនេះវា មានច្រើនយ៉ាង មន្រ្តីខាងលោកដោយមានការផ្តល់ច្រើនពេកអាចមានការច្រឡំ ហើយបើមានការខុសឆ្គងសុំធ្វើជាថ្មីឡើងវិញចុះ ។

លោក **សួរ្យ ទិត្យ** បញ្ហារាប់សន្លឹកឆ្នោត លោក បានបញ្ជាក់ថា គជប ធ្វើទៅតាមបទបញ្ជានិងនីតិវិធី គជប មិនអាចធ្វើអ្វីដែលខុសបានទេ តែបើសភាពដែលលឿនពេក គជប នឹងធ្វើការកែលំអរបញ្ហានេះ ធ្វើយ៉ាងណាអោយគណបក្សនយោបាយដែលចូលសង្កេតការណ៍ទាំងអស់ហ្នឹង លោក បានឃើញគ្រប់ៗគ្នា ។

ហើយបញ្ហាលទ្ធផលបណ្តោះអាសន្ន គឺ លោក សំនូមពរទៅវិញថា ពេលរាប់សន្លឹកឆ្នោតហ្នឹងទោះឈ្នះក្តី ចាញ់ក្តី សូមអោយគណបក្សនយោបាយទាំងអស់នៅដល់ចប់ការរាប់ ព្រោះកន្លងមកមានឃុំខ្លះដោយមើលឃើញថាគណបក្សរបស់ខ្លួនចាញ់ ចេញបាតដល់២-៣ថ្ងៃក្រោយមក បានមកទាររកលទ្ធផលពីមេឃុំ វាមានអញ្ចឹងដែរ ហើយឃុំធ្វើមិនទាន់ចប់ ក៏មិនអាចជូនបានដែរ ។ ឆ្នាំ២០០៧នេះ គឺសូមអោយគណបក្សនយោបាយកត់យកដោយខ្លួនឯង គណៈកម្មាធិការអ្នករៀបចំការបោះឆ្នោតនេះមិនបានកត់ជូនទេ ក្រោយពីរៀបចំលទ្ធផលចប់សព្វគ្រប់ហើយបិតជញ្ជាំង ហើយកត់យកដោយខ្លួនឯង ដូច្នេះដើម្បីកត់យកបានសូមលោកនៅដល់ចប់ដើម្បីបានលទ្ធផលចុងក្រោយ ។

ហើយការខុសអក្ខាវិរុទ្ធបន្តិចបន្តួច ដូចជាសុខ និងក និងខអីនេះ បើតាម លោក ក្តាប់បាន កាលលោក ទៅប្រជុំនៅពេលចុះឈ្មោះ និងពិនិត្យបញ្ជីឈ្មោះនេះកាលលើកឡើងក្រៅផ្លូវការទេ របស់ គជប ថាការខុសបន្តិចបន្តួច គជប អាចធ្វើការអធ្យាស្រ័យអោយបាន ។ ប៉ុន្តែការខុសធ្ងន់ធ្ងរពេក ដូចជាក្នុងអត្តសញ្ញាណប័ណ្ណចុះភេទស្រី ទៅប្រុស ចុះភេទប្រុសទៅស្រី បើបែបនេះ គជប ឱ្យប្រើ១០១៨ទៅ ព្រោះបើយើងកែអត្តសញ្ញាណប័ណ្ណត្រូវការប្រើពេលយូរណាស់ ។

ដើម្បីកុំអោយមានទំនាស់ លោក បានបញ្ជាក់ថានៅលើលោកនេះមិនអាចថាមិនមានទំនាស់ទេ ទោះបីព្រះសង្ឃកាន់ធមិរាល់ថ្ងៃក៏លោកមានទំនាស់ដែរ ប៉ុន្តែយើងនឹងធ្វើយ៉ាងណាដើម្បីកាត់បន្ថយទំនាស់ពីច្រើនមកតិច ។

ចំពោះការរាំងការឃោសនា និងការរាំងការបោះឆ្នោត គឺផ្ទុយនិងច្បាប់ ផ្ទុយនិងបទបញ្ជា ផ្ទុយនិងក្រមសីលធមិ ហើយបើមានអ្នករាំងមែន អ្នករាំងនោះគឺខុសនិងច្បាប់ហើយ គជប មានការដាក់ទោសទៅតាមនោះដែរ ។

ចំពោះការលើកឡើងថា មានឈ្មោះដូចគ្នា ថ្ងៃខែដូចគ្នា នេះជាកំហុសរបស់ការិយាល័យមិនបានពិនិត្យអោយបានត្រឹមត្រូវព្រោះមុននឹងអោយគាត់ចូលទៅបោះឆ្នោត យើងត្រូវសួរគាត់ លោកឈ្មោះអី យើងត្រូវមើលផ្ទៀងផ្ទាត់និងបញ្ជីយើងដូច បានយើងអោយចូល បើដូចតែឈ្មោះថ្ងៃខែអត់ដូច ហើយយើងនៅតែអោយចូលទៀតវាជាកំហុសហើយ ។

លោក **ឡារី ស្រ្តេនូ** បានលើកឡើងនូវរបាយការណ៍ខ្លះៗ ដែលលោកទើបតែមកពីជួបជាមួយឯកឧត្តមអភិបាលខេត្តនៅពេលព្រឹកនេះ ។ លោក មានការរីករាយណាស់ដោយបានឮឯកឧត្តមអភិបាលខេត្តបានឆ្លើយនៅក្នុងនាមជាអាជ្ញាធរខេត្តដែលឯកឧត្តមមានឆន្ទៈនិងបានសន្យាថា នឹងឆ្លើយតប ឬដោះស្រាយចំពោះបញ្ហានានា ទៅលើរាល់បណ្តឹង ឬការលើកឡើងរបស់ភាគីពាក់ពន្ធ័នៅក្នុងការបោះឆ្នោតនៅក្នុងខេត្តស្វាយរៀងនេះ ។ លោកសូមលើកឡើងនូវចំនុចពីយ៉ាងគឺ ទី១ ទាក់ទងនិងការជូន និងផ្តល់ពតិមានប្រក្របដោយសុក្រឹត្យភាពត្រឹមត្រូវ ជាក់ស្តែងវិទ្យាស្ថាន CDRI គិតថាការជូន និងការចែករំលែកនូវពតិមានដ៏សុក្រឹត្យ ជាក់លាក់និងត្រឹមត្រូវ គឺជាជំហានមួយដែលយើងកសាងនូវតម្លាភាព យុត្តិធមិ ដែលយើងអាចទទួលបានទាំងអស់គ្នា ។ ចំនុចទី២ ក្នុងនាមលោក ជាជនបរទេសដែលរស់នៅប្រទេសអូស្រ្តាលី ហើយមកធ្វើការនៅក្នុងប្រទេសកម្ពុជាជាង៣ឆ្នាំមកនេះ លោក គ្រាន់តែចែករំលែកថា ប្រទេសអូស្រ្តាលីទើបតែចាប់កំណើតនៅក្នុងពេលថ្មីនេះទេ ហើយមានការកសាងនូវធម្មនុញ្ញប្រកបដោយលទ្ធិប្រជាធិប

តេយ្យ ទើបតែរយៈពេល១០០ឆ្នាំជាងនេះទេ ហើយក្នុងរយៈពេលនេះ គឺយើងទទួលបានមេរៀននិងបទពិសោធន៍ល្អៗជាច្រើន ទី១ទាក់ទងទៅនិងដំណើរការនៃការកសាងនូវធម្មនុញ្ញប្រកបដោយលទ្ធិប្រជាធិតេយ្យនេះ គឺទាមទាររយៈពេលយូរអង្វែងណាស់ ហើយជាបទពិសោធន៍មួយទៀតនោះ ដើម្បីទទួលបាននូវធម្មនុញ្ញប្រកបដោយលទ្ធិប្រជាធិតេយ្យពិតប្រាកដ ទាមទារនូវការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។ លោក បានបញ្ជាក់ថា នៅលើពិភពលោកយើងនេះ ទំរង់នៃលទ្ធិប្រជាធិតេយ្យ គឺអាស្រ័យទៅលើ គំរូវការរបស់ប្រជាពលរដ្ឋក្នុងប្រទេសនិមួយៗ ។ បញ្ហាទាំងអស់នេះហើយដែលវិទ្យាស្ថាន CDRI បានមើលឃើញថា យន្តការ ឧប់សែល ជាយន្តការមួយដ៏សំខាន់ ។ លោក សូមថ្លែងនូវអំណរគុណចំពោះអស់លោក លោកស្រីដែលជាវាគ្មិននៅក្នុងការចូលរួមប្រជុំ និងបានលើកឡើងនូវមតិយ៉ាងផុសផុល ហើយក៏សូមអរគុណលោក ឱក សេរី សោភ័ក្តិ ដែលជាអ្នកសំរបសំរួលប្រកបដោយប៉ិនប្រសព្វនៅក្នុងកិច្ចប្រជុំនេះ លោកបានថ្លែងអំណរគុណចំពោះខាង UNDP ដែលបានគាំទ្រកម្មវិធី ឧប់សែល នេះ ។

លោក **ឱក សេរី សោភ័ក្តិ** មានចំនុចពីដែលសូមជម្រាបអង្គប្រជុំ ទី១ គឺការកែប្រែតិយាបទ ហើយនិងការពិចារណា និងផ្នត់គំនិតនៅក្នុងសង្គមខ្មែរយើង ។ យើងបានសន្តិភាពដោយលំបាកណាស់ ពេលដែលបានចូលមកនូវអាគារដ៏ល្អប្រណិតបែបនេះ តែងតែមានការរំភើបចិត្ត ហើយគិតក្នុងចិត្តថា ធ្វើយ៉ាងណាដើម្បីថែរក្សាអាគារ ផ្លូវថ្នល់ដ៏ល្អប្រណិតនេះអោយល្អ លោក គិតថា មានតែវិធីមួយគត់ដែលយើងធ្វើមួយព្រឹកនេះ គឺការជជែកគ្នាដោយត្រង់ទៅត្រង់មក ។ ទំនាស់បើយើងចេះគ្រប់គ្រង គឺជាការ កសាងមួយល្អណាស់ ព្រោះបើកឱកាសអោយយើងសំលឹងអ្នកឯទៀតដោយខ្សែរភ្នែកខុសពីមុន កាលពីពេលដែលយើងមិនដឹង គ្រាន់តែឮគេថា យើងស្អប់ទាំងមិនទាន់ស្គាល់ ដល់ពេលយើងជួបអ្នកហ្នឹងផ្ទាល់ យើងអង្គុយស្តាប់គេ បានយើងចាប់ផ្តើមយល់ថា បានជាគេមានគំនិតខុសពីយើង មកពីគេមានហេតុផល ។ ដូច្នេះការទាស់គ្នាមិនប្រាកដថាអាក្រក់ទាំងអស់ទេ អោយតែយើងចេះគ្រប់គ្រងទំនាស់ ។ នៅក្នុងព្រឹកនេះយើងលើកបញ្ហាដែលជាទំនាស់ច្រើនណាស់ ប៉ុន្តែយើងលើកឡើងដោយសភាពថ្លៃថ្នូរ ដោយការគោរពគ្នាទៅវិញទៅមក ។ ទី២ លោក សូមស្នើរជូនទៅខាងវិទ្យាធិការ និងនិស្សិតនៅសកលវិទ្យាល័យនេះទាំងអស់ ដោយសារបានទទួលនូវការស្វាគមន៍យ៉ាងកក់ក្តៅពីសកលវិទ្យាធិការ លោកសូមជូន បើថ្ងៃក្រោយទៅនិស្សិតនិងខាងវិទ្យាធិការចង់អោយលោកមកធ្វើជា គ្រូលោក នឹងស្ម័គ្រចិត្តមកធ្វើ៣-៤ថ្ងៃ ជាប់គ្នាហើយមិនមានយកលុយទេ សណ្ឋាគារដែលលោកស្នាក់ គឺចេញខ្លួនឯងទាំងអស់ ហេតុអីបានអញ្ចឹង ? សព្វថ្ងៃនេះ លោក បានរៀបចំវគ្គបណ្តុះបណ្តាលមួយហៅថា វគ្គបណ្តុះបណ្តាលអ្នកជំនាន់ថ្មី ហៅថាវគ្គទំពាំងថ្មី ហើយកំពុងតែសរសេរទស្សនៈហ្នឹង នៅក្នុងសៀវភៅមួយបន្តិចទៀតមានចេញហើយ គឺដោយសារយកលុយកាក់ដែលបានមកពីការធ្វើជាទីប្រឹក្សាអង្គការអន្តរជាតិធំៗហ្នឹង យកមករៀបចំផ្ទាល់ដើម្បីចង់ដឹងថា តើយើងអាចហ្វឹកហាត់យុវជន យុវនារីដែលចេញពីសាលាថ្នាក់បរិញ្ញាប័ត្រនោះ អោយក្លាយទៅជាអ្នកដែលស្គាល់នូវតំម្លៃ ស្គាល់ការគោរពពេលវេលា ស្គាល់ភាពស្អាតស្អំ ស្គាល់ការថែរក្សាបរិស្ថានជាតិ សម្បត្តិជាតិនោះបាន ឬមិនបាន? លោក ធ្វើបាន២វគ្គ ហើយ វគ្គឆ្នាំ២០០៥ ដែលគេហៅខ្លួនគេថា ជាវគ្គជំនាន់គំរូ ហើយវគ្គ ២០០៦នេះ ដែលគេទើបតែនិងបញ្ចប់ខែមុនហ្នឹង ដែលគេហៅខ្លួនគេថា ជំនាន់សាមគ្គី ឥឡូវកំពុងរៀបចំវគ្គថ្មីទៀត ហើយ លោក និងរៀបចំ៥វគ្គ ។ លោក នឹងធ្វើរឿងនេះនៅក្នុងសកលវិទ្យាល័យស្វាយរៀង បើសិនជាសកលវិទ្យាល័យត្រូវការនៅក្នុងវិស័យអភិបាលកិច្ចល្អ នៅក្នុងវិស័យលទ្ធិប្រជាធិតេយ្យ និងក្នុងវិស័យការកសាងសន្តិភាព និងការដោះស្រាយទំនាស់ ។